សារព័ត៌មាន ខ្មែរប៉ុស្ត៍ ស.រ.អា

KhmerPost USA

Free Copies

Email:Khmerpostusa@gmail.com
www.khmerpostusa.com

Vol. 15. Issue 367, Nov 07, 2024 | Direct: 978-656-8141 Lowell - Lynn - Revere - MA * Providence - Cranston - RI

# លទ្ធផលចម្លែក នៃការបោះឆ្នោតប្រធានាធិបតីស.រ.អាឆ្នាំ២០២៤

ដោយ ខ្មែរប៉ុស្តិស.រ.អា

ថ្ងៃទី៦ វិច្ឆិកា ២០២៤

ប្រជាពលរដ្ឋអាមេរីកាំង បានតាមដានការបោះឆ្នោតប្រធានាធិបតីរបស់គេរហូតដល់ទាបភ្លឺ នៃថ្ងៃទី៦វិច្ឆិកា លទ្ធផលដ៏គួរឲ្យភ្ញាក់ផ្អើលបានទៅលោក ឌណាល ត្រាំ ។ ការស្ទង់បតិនៅ១សប្តាហ៍កន្លងមក រហូតដល់នៅថ្ងៃទី៤ បានឲ្យ កាម៉ាឡា ហារីស ឈ្នះជាមធ្យមពពិន្ទុ ប៉ុន្តែនៅព្រហ៊ាមថ្ងៃទី៦ ស្រាប់តែលោកត្រាំបានទទួលលទ្ធផលបានដំណាងរដ្ឋចំនួន២៧៧ ដែលជាចំនួនលើសពីសេចក្តីត្រូវការសម្រាប់ឈ្នះ(ដំណាងរដ្ឋ២៧០)រួចស្រេចទៅ

តទៅទំព័រទី១១



លោក ឌណាល ត្រាំ ជាប់ឆ្នោត ក្លាយជាប្រធានាធិបតី ទី៧៤ នៃសហរដ្ឋអាមេរីក

## កម្ពុជាអាចនឹងបាត់បង់ដី ៥១គីឡូម៉ែត្រការ៉េ ជាប់ព្រំដែនក្នុងខេត្តមណ្ឌលគិរី

ដោយ លី ហេង

អ្នកតាមដានបញ្ហាព្រំដែន លោក អ៊ុំសំអាននិយាយថាទឹកដីខ្មែរ៥១គីឡូម៉ែត្រ

តទៅទំព័រទី១២

## Cambodia May Lose 51 Square Kilometers of Land Bordering Mondulkiri Province

A border observer Oum Sam An says 51 square kilometers of Cambodian land bordering Mondulkiri province will soon fall into Vietnamese hands if Cambodia does not protest while Vietnam is standing there and building



បង្គោលព្រំដែននៅខេត្តមណ្ឌលគិរីជាប់ប្រទេសវៀតណាម

## អ្នកគួរដឹង ពីថ្ងៃបោះឆ្នោតសហរដ្ឋអាមេរិក តើលោកអ្នកនឹងត្រូវបោះឆ្នោតឲ្យដំណែងណាខ្លះ?

ដោយ ខ្មែរប៉ុស្តិស.រ.អា

ឡូវែល ទី២៩តុលា២០២៤

នៅថ្ងៃទី ៥វិច្ឆិកា ២០២៤ លោកអ្នក



នឹងចេញទៅបោះឆ្នោតជ្រើសរើសប្រធានាធិបតី តែនៅថ្ងៃនោះដែរ ប្រជាពលរដ្ឋអាមេរីកាំង ក៏មានភារកិច្ចបោះឆ្នោតជ្រើសរើសបេក្ខជនសម្រាប់ដំណែងសំខាន់ៗឯទៀតច្រើនដែរ មាន៖

១ ដំណែងប្រធានាធិបតី នឹង អនុប្រធានាធិបតី (President & Vice President )

២ ដំណែងសមាជិកព្រឹទ្ធសភាក្នុងសភាជាន់ខ្ពស់ (Senator in Congress)

តទៅទំព័រទី២៣

# តារា ហុង ឈ្នះឆ្នោតជុំទី១ សម្រាប់តំណែង តំណាងរដ្ឋម៉ាសាឈូសិត សង្កាត់លេខ១៨

ដោយ ខ្មែរប៉ុស្ត៍ស.រ.អា
ថ្ងៃទី១៥|តុលា|២០២៤ ឡូវែល

លោក តារា ហុង អាយុ២៤ ឆ្នាំ បានឈ្នះ«ឆ្នោតជំរុស» ជាបេក្ខជនតំណាងរដ្ឋ ដ៏ក្មេងជាងគេ នៅសង្កាត់លេខ១៨រដ្ឋម៉ាសាឈូសិតក្នុងចំណោមបេក្ខជនមកពីគណបក្សប្រជាធិបតេយ្យ ៣នាក់ ដែលបានឈរឈ្មោះ កាលពីខែកញ្ញាមុន, លោក តារា ហុង ពានទទួលសន្លឹកឆ្នោត ១១១៩សន្លឹក ឈ្នះជាបេក្ខជនតំណាងឲ្យគណបក្សប្រជាធិបតេយ្យ ក្នុងការប្រកួតជុំទី១ លោកបានឈ្នះបេក្ខជនមានដើមកំណើតខ្មែរម្នាក់ទៀត ឈ្មោះ រ៉ាឌី ម៉ម ដែលធ្លាប់បានកាន់ដំណែងនេះ ១០ឆ្នាំរួចមកហើយ ។ លោក តារា ហុង នឹងទៅជួបប្រកួត តទល់នឹងបេក្ខជនឯករាជ្យម្នាក់ទៀត នៅចុំទី២ថ្ងៃទី ៥វិច្ឆិកា ឆ្នាំ២០២៤ ខាងមុខ ជាការប្រកួតផ្តាច់ព្រាត់ ថ្ងៃបោះឆ្នោតលើកក្រោយនោះក៏ចំថ្ងៃបោះឆ្នោតប្រធានាធិប សហរ្ឋអមេរីកផងដែរ។

ជួបសម្ភាសន៍ជាមួយ«ខ្មែរផុសស.រ.អា.»លោក តារា ហុង បានឆ្លើយនឹងសំនួរជាច្រើន ដើម្បីឲ្យបានយល់ពីបុគ្គលិកលក្ខណ៌របស់បេក្ខជជនដ៏ថ្មីថ្មោងក្នុងនយោបាយនៃតំបន់១៨នេះ៖

**សំនួរ៖ តើលោកមានសង្ឃឹមប៉ុណ្ណានៅជុំទី២ខាងមុខ?**

តារា ហុង: ខ្ញុំមានសង្ឃឹមច្រើនពីព្រោះខ្ញុំបានធ្វើការប្រស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋច្រើនណាស់ សុំគេឲ្យគាំទ្រខ្ញុំ

**សំនួរ៖តើលោកត្រៀមធ្វើនយោបាយតាំងពីពេលណាមក?**

តារា ហុង៖ យូរដែរហើយ! ខ្ញុំរៀននៅវិទ្យាល័យឡូវែលឆ្នាំ២០១៨បន្ទាប់មកខ្ញុំទៅរៀននៅ«យូម៉ាស់ឡូ»ក្នុងរយៈពេលនោះ ខ្ញុំបានធ្វើការជាមួយសមាគមខ្មែរនឹងស្ម័គ្រចិត្របំរើសង្គមច្រើនកន្លែងជាហេតុធ្វើឲ្យខ្ញុំបានស្គាល់នឹងយល់ពីសេចក្តីត្រូវការរបស់សង្គម ព្រមទាំងអ្នកបំរើសង្គម បានច្រើន នោះហើយជាហេតុផលដែននាំឲ្យខ្ញុំចូលធ្វើនយោបាយលឿនយ៉ាងនេះ

**សំនួរៈតើនៅពេលឈរឈ្មោះនោះលោកមើលឃើញអ្វីខ្លះ ដែលខ្វះខាតក្នុងសង្គមខ្មែរ?**

តារា ហុងៈ នៅតំបន់ដែលខ្ញុំឈរជាដំណាងរាស្ត្រនោះ មានពលរដ្ឋខ្មែរយើងចំនួនច្រើនមានក្រុម«ឡាទីណូ»មានក្រុមស្បែកខ្មៅក៏ច្រើន គឺជាតំបន់ដែលមានជនជាតិភាគតិចចំនួនច្រើន ខ្ញុំបាន



សន្យាថានឹងមកជួបម្ចាស់ឆ្នោតឲ្យបានច្រើនដង ដើម្បីទទួលយកនូវបញ្ហានានាទៅជួយដោះស្រាយ ពួកគេចង់ឲ្យមានការកែរប្រែនៅក្នុងតំបន់លេខ១៨នោះ គេថាកាលពីអាណត្តិមុនៗគេពុំបានឃើញពូ រ៉ាឌី ម៉ម ចេញមកជួបពួកម្ចាស់ឆ្នោតទេ តាំងពី៥អាណត្តិមកហើយ ...

**សំនួរៈ ដូច្នេះតើអ្វីទៅដែលនាំឲ្យលោក រ៉ាឌី ម៉ម ជាប់ឆ្នោតបានដល់៥អាណត្តិ តើគេពេញចិត្តលោករ៉ាឌី ម៉ម នៅត្រង់ណា?**

តារា ហុងៈ កាលពីអាណត្តិទី១ទី២របស់ រ៉ាឌី ម៉ម គេចង់ឃើញក្រុមខ្មែរចូលក្នុងសភា តែនៅអាណត្តិទី៣ទី៤មានបេក្ខជនខ្មែរផ្សេងទៀត ក៏បានចូលទៅឈរឈ្មោះដែរ បានធ្វើឲ្យបែកសន្លឹកឆ្នោត តែពូ រាឌី ម៉ម នៅរក្សាដំណែងបានដោយអ្នកកាន់ដំណែងតែងបានចំណេញប្រជាប្រិយភាព ហើយខ្មែរយើងក៏មិនសូវបានចេញទៅបោះឆ្នោតទេ...តែចុងក្រោយនេះពេលបោះឆ្នោតជុំទី១ ថ្ងៃទី៩ខែមិនា២០២៤ខ្ញុំបានទៅគោះទ្វារគ្រប់ផ្ទះ នៅតំបន់«ហាយឡិន»នឹងតំបន់ផ្សេង សូមអញ្ជើញគេ

តទៅទំព័រទី១០

# Dara Hong Wins First Round of Massachusetts Representative in 18th District

By Khmerpost USA

Dara Hong, 24, won the "election" as the youngest state candidate in the 18th District of Massachusetts out of three Democrat candidates who ran last September.

Dara Hong received 1119 votes, won as a candidate to represent the Democratic Party in the first round, he defeated another candidate of Cambodian origin, Rady Mam, who has held this position for 10 years.

Dara Hong will face another independent candidate in the second round on November 5, 2024, the next election day, also on the day of the US presidential election.

In an interview with "Khmer Post USA", Dara Hong answered many questions to understand the characteristics of the new candidates in the politics of the 18th District:

Question: How much hope do you have in the second round?

Dara Hong: I have high hopes because I have communicated with a lot of people asking for their support.

Question: When have you been ready for politics?

Dara Hong: It's been a long time! I studied at Lowell High School in 2018, then I went to study at "UMASS Lowell". During that time, I worked with the Cambodian Association and volunteered to serve the community in many places. As a result, I got to know and understand the needs of society and many social workers, and that is why I got involved in politics so fast.

Question: When you ran for office, what did you see that was lacking in Cambodian society?

Dara Hong: In the area where I stand as a member of parliament, there are a lot of Cambodians, a lot of "Latinos", a lot of black people, an area with a lot of ethnic minorities, I promised to meet the voters many times to solve the problems, to help solve them, they want to make changes in 18th District. It is said that in the previous mandate, they did not see Radi Mam coming out to meet the voters in the last five mandates…

Question: So, what led to Rady Mam being elected for 5 terms, what is Rady Mam preferred?

Dara Hong: In the first and second mandates of Rady Mam, they wanted to see the Khmer group enter the National Assembly. But in the third and fourth term, other Cambodian candidates also ran for office, causing the ballots to be divided, but Radim Mam retained his position.

As the incumbents have always gain popularity and popularity, we Cambodians do not go to the polls very often ... but recently, during the first round of voting on March 9, 2024, I knocked on the door of every house in "Highland" and other areas, invited them to go to the polls, and the number of people who went to the polls has increased by more than 300 votes, which was why I won 182 votes over Rady Mam.

Question: Do you know that voters have changed their minds and do not want to vote for Rady Mam or new people just came out?

Dara Hong: Some people also changed their minds, because I went to knock on the door, I talked to the voters in front of them, asking them to give me the opportunity to serve our community, what is important for our 18th Districts, the importance of education sector, lower housing price, It is a good opportunity to explain to the

Please see /10

ក្រុមការងារសហគមន៍
កិច្ចប្រជុំក្រុមប្រឹក្សាភិបាល
ថ្ងៃពុធ ទី ០៤/១២/២៤ ម៉ោង ៦:៣០ ល្ងាច បន្ទប់សន្និសីទជាន់ទី២
126 Phoenix Ave, Lowell
ស្វាគមន៍សាធារណៈជន ដើម្បីចូលរួម សូមកក់ទុកជាមុន RSVP៖
ទំនាក់ទំនង sruas@commteam.org
COMMUNITY TEAMWORK
Building Communities Changing Lives
Community Teamwork
Board of Directors Meeting
Community Teamwork
Board of Director Meeting
Wednesday, December 4, 2024 at 6:30 P.M.
Marjorie McDermott Board Room
155 Merrimack Street – 2nd Floor,
Lowell, MA 01852
Public Welcome
RSVP sruas@commteam.org to virtually attend

តមកពីទំព័រទី ០១

# កម្ពុជាអាចនឹងបាត់បង់ដី៥១គីឡូម៉ែត្រ

ការ៉េជាប់ព្រំដែនស្ថិតនៅក្នុងខេត្តមណ្ឌលគិរីនឹងធ្លាក់ក្នុងដៃវៀតណាមគ្រប់គ្រងទាំងស្រុងក្នុងពេលដ៏ខ្លី បើកម្ពុជាមិនប្តឹងតវ៉ាខណៈវៀតណាមកំពុងឈរជើងនៅទីនោះ និងធ្វើសំណង់រឹង ដោយគ្មានការរំខានពីគណបក្សកាន់អំណាច លោក អ៊ុំ សំអាន តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ដែលជាអ្នកតាមដានបញ្ហាព្រំដែន បានបង្ហោះសារនៅលើបណ្តាញសង្គម កាលពីថ្ងៃទី១២ កញ្ញា នេះថាដីខ្មែរទំហំប្រមាណជាង ៥១គីឡូម៉ែត្រការ៉េ នៅតំបន់ដាក់ដាំដាក់ហ៊្វិត ស្ថិតក្នុងខេត្តមណ្ឌលគិរី ត្រូវបានវៀតណាមគ្រប់គ្រង ប្រភពបន្តថារដ្ឋាភិបាលនៅតែអះអាងថានឹងបន្តចរចារទ្វេភាគីបន្តទៀតពីបញ្ហាតំបន់នោះ ដោយមិនព្រមប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ អាយ.ស៊ី.ជ(I.C.J) នោះទេ សម្រាប់លោក អ៊ុ សំអាន ថាកម្ពុជានឹងគ្មានសង្ឃឹមបានដីទំហំ ៥១គីឡូម៉ែត្រការ៉េ នោះមកវិញទេក៏ព្រោះតែរដ្ឋាភិបាល មិនព្រមប្តឹងករណីនេះទៅតុលាការយុត្តិធម៌អន្តរជាតិខណៈតំបន់នោះមិនទាន់បោះបង្គោលនោះឡើយ លោក អ៊ុ សំអាន ឲ្យដឹងបន្ថែមទៀតថ្ងៃទី១២កញ្ញា នេះថាទឹកដីខ្មែរនៅតំបន់នោះ នឹងបាត់បង់ទៅវៀតណាមបន្ថែមទៀត បើមេដឹកនាំគ្រួសារត្រកូលហ៊ុន នៅតែខ្លាចអំណាចវៀតណាមមិនប្រញាប់ទាមទារមកវិញនោះទេ ដី៥១គីឡូម៉ែត្រការ៉េ និងគឺវៀតណាមគ្រប់គ្រងទាំងស្រុងតែម្តងយើងអត់បានគ្រប់គ្រងរួមជាមួយវៀតណាមនោះទេ ហើយមូលហេតុដែលថាដីហ្នឹងគញរប់គ្រងដោយវៀតណាម អាចនឹងបាត់បង់ទៅប្រទេសវៀតណាមទាំងស្រុងទៅថ្ងៃអនាគតដោយសារតែ ព្រំដែនបច្ចុប្បន្នដើរដោយព្រំដែនបណ្តោះអាសន្នទំដែន បច្ចុប្បន្នដើរនៅតាមព្រែកដាក់ដាំទេ អត់បានដើរនៅតាមអាព្រែកដាក់ហ៊្វិតនោះទេ បាទ! ហើយការពិតតាមសារាចររបស់អគ្គទេសាភិបាលបារាំងប្រចាំនៅឥណ្ឌូចិន ឆ្នាំ១៩១៤ ហ្នឹងគឺព្រំដែនកម្ពុជា-វៀតណាមដើរនៅព្រែកដាក់ហ៊្វិតៗ ហ្នឹងគឺដោយសារតែភាសារវៀតណាម ឯភាសារខ្មែរយើងគឺដាក់ហ៊ុច ឬគេហៅអូរហ៊ុច នេះបើតាមសម្តីលោក អ៊ុ សំអាន។

លោក អ៊ុ សំអាន បានអះអាងថាបច្ចុប្បន្នតំបន់ប្រទាញប្រទង់គ្នានោះ គឺវៀតណាមគ្រប់គ្រងទាំងស្រុងដោយបានបញ្ជូនប្រជាពលរដ្ឋគេមកដាំដំណាំដំឡូង និងធ្វើចម្ការ ហើយផ្នែកខ្លះបានសាងសង់រចនាសម្ព័ន្ធជាច្រើនទៀតតំបន់ហ្នឹងវាបាត់បង់ទៅវៀតណាមក្នុងពេលអនាគត នៅពេលដែលពេលនេះគ្រប់គ្រងទាំងស្រុងហើយ យើងដឹងហើយនៅពេលដែលវៀតណាមគ្រប់គ្រងទាំងស្រុងហើយ គឺយើងមិនអាចយកដីហ្នឹងបានមកវិញនោះទេ បើសិនជាយើងមិនប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិនៅទីក្រុងឡាអេហាស ប៉ុន្តែបើសិនជាអាចមានរដ្ឋាភិបាលថ្មីដែលគេមិនជំពាក់គុណយួនគេជារដ្ឋាភិបាលដែលឯករាជ្យ អាហ្នឹងប្រាកដជារដ្ឋាភិបាលហ្នឹងអាចយកដី ៥១គីឡូម៉ែត្រការ៉េ បានពីយួនមកវិញដោយយើងប្តឹងទៅវៀតណាមទៅតុលាការអន្តរជាតិនៅទីក្រុងឡាអេ ឬក៏យើងអាចរកភាគីទីបីជួយដូចជាបារាំងអីអោយមកជួយអន្តរាគមន៍រឿងហ្នឹងហាស! ហ្នឹងបានយើងអាចបានដីហ្នឹងមកវិញ បើតាមលោក អ៊ុ សំអាន បញ្ជាក់បន្ថែម ទាក់ទិននឹងបញ្ហានេះលោកបណ្ឌិតសុខ ទូចប្រធានរាជបណ្ឌិត្យ

តទៅទំព័រទី១៧

# Cambodia May Lose 51 Square Kilometers of Land Bordering Mondulkiri Province

From Page 01

strong constructions without any interference from the ruling party, CNRP lawmaker Oum Sam An, who monitors border issues, posted a message on social media on September 12 that more than 51 square kilometers of Cambodian land in the Dak Dam and Dak Huot area in Mondulkiri province is under Vietnamese control. The government has said it will continue to hold bilateral talks on the region without filing a complaint with the International Court of Justice (ICJ), sources said.

For Oum Sam An, Cambodia will have no hope of regaining 51 square kilometers of land because the government has refused to take the case to the International Court of Justice, as the area has not yet been demarcated, Oum Sam An said. September 12 that more Khmer land in that area will be lost to Vietnam if the Hun dynasty are still afraid that Vietnamese power and will not reclaim in a hurry, 51 square kilometers of land will be completely controlled by Vietnam and lost to Vietnam completely in the future because the current border is a temporary border, the current border is along the Dak Dam canal, not along the Dak Huot canal. In fact, according to the circular of the Governor General of France in Indochina in 1914, the Cambodian-Vietnamese border is lining in Prek Dak Huot. This is because of the Vietnamese language, while our Khmer language is Dak Huch or O Huch, according to Mr. Oum Sam An.

Oum Sam An claimed that the conflict zone is now completely controlled by Vietnam, sending people to plant cassava and plantations, and some have built more structures. That area will be lost to Vietnam in the future, when it is now in full control, and we know that when Vietnam is in full control, we will not be able to take back that land if we do not appeal to the International Court of Justice in The Hague. But if there can be a new government that is not indebted to Vietnam, it is an independent government, surely it can take back 51 square kilometers of land from Vietnam by filing a complaint against Vietnam at the International Court of Justice in The Hague or we can find a third party like France come to intervene.

Well, we can get that land back, according to Mr. Oum Sam An, who further confirmed this issue, Dr. Sok Touch, President of the Royal Academy of Cambodia and a researcher on the government's border issues, denied this claim.

Mr. Sok Touch said that he did not go to Vietnam as mentioned, but just let him go and see if there were any problems, it remains the same, I walked through it and I got bitten by leches all over my body. And there is no approval yet, and not 50 kilometers, it is 27 kilometers, let him go and see, I'm hard to say because now it becomes an illness of gossip and without reality.

Please see /17



សមុទ្រឈើនៅខេត្តមណ្ឌលគិរី

# បញ្ហាតម្លៃកសិផលចំពោះកសិករជារឿងដដែលៗ

ដោយ លី ហេង

ប្រជាកសិករនៅតាមបណ្ដាខេត្តមួយចំនួន បាននិយាយថាពួកគាត់នៅតែជួបវិបត្តិដដែលៗ ទាក់ទងនឹងតម្លៃកសិផលចុះថោកនារដូវប្រមូលផល ដែលបញ្ហានេះរាលដាលដល់របរចិញ្ចឹមសត្វផ្សេងៗ ធ្វើឲ្យដកខ្លួនមិនរួចពីបំណុលពីមួយឆ្នាំទៅមួយឆ្នាំ កសិករនៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ បានថ្លែងប្រាប់នៅវិទ្យុវីអូឌីនៅថ្ងៃទី១១ខែកញ្ញា ថាមន្ត្រីកសិកម្មចុះមកជួបពលរដ្ឋនៅពេលមានការបង្ហោះលើបណ្ដាញសង្គម និងរងការរិះគន់ពីរពលរដ្ឋតែប៉ុណ្ណោះ ហើយបានបន្តថាឈ្មួញទិញស្រូវតែងតែប្រើល្បិចដដែលៗ ដោយឲ្យកសិករច្រូតស្រូវសើមដាក់ក្នុងបាវ លុះមកដល់ពេលល្ងាចគេទម្លាក់តម្លៃទៅតាមចិត្ត ដែលធ្វើឲ្យពួកគាត់បង្ខំចិត្តលក់ទោះបីខាតក៏ដោយ ពួកគាត់ថាការដែលឈ្មួញបន្តធ្វើតាមទំនើងចិត្តបែបនេះ ដោយសាររដ្ឋាភិបាលមិនមានគោលការណ៍កំណត់តម្លៃស្រូវជាក់លាក់ និងតាមដានឲ្យបានជិតដល់ទៅលើឈ្មួញ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ ហ្នឹងឯងយើងចង់អោយអី..



រថយន្តធំៗដឹកកសិផលខ្មែរទៅលក់នៅវៀតណាម

ខាងក្រសួងគេយល់ថាៗតម្លៃស្រូវហ្នឹងអោយគេដឹងថា ចេញពីខាងណាអោយពិតប្រាកដហាស ព្រោះយើងដឹងថា

តទៅទំព័រទី២០

# Agricultural Prices for Farmers Face Recurring Crisis

By Ly Heng

Farmers in some provinces say they are still experiencing recurring crises related to lower agricultural prices during the harvest season, which has spread to other livestock businesses, making it impossible to get out of debt year after year. Farmers in Mongkul Borei district, Banteay Meanchey province, told VOA Khmer on September 11 that agricultural officials only visited farmers when they posted on social media and were criticized by two people, adding that rice traders often use repetitive tricks by allowing farmers to harvest wet rice in sacks in the evening, they lower the price at will, forcing them to sell despite losing money and set specific rice prices, To closely monitor the traders and mill owners, we want the Ministry understands that the price of rice, to let them know exactly where it comes from. Every day, it's hard to know which side is right. Farmers know that buyers set the price, the price depends on the buyer's word of mouth. There is profit if a farmer has 4 to 5 tons of rice. It is not profitable if a farmer harvests only 3 tons of rice per hectare, it is 3 million. Price of rice is under 1000 Riel per Kilogram forcing some farmers to sell at the loss. A video calls on agricultural officials to solve this problem, in the evening, officials went to check that traders have increased the

Please see /20

AccuCare
Home Care Agency
ភ្នាក់ងារថែទាំអ្នកជំងឺតាមផ្ទះ
Group Adults Foster Care Program
កម្មវិធីថែទាំមនុស្សពេញវ័យ
144 Merrimack Street • Suite 404
Lowell, MA 01852 • 617-783-7177



Open for enrollment.
Persons with disability and chronic illnesses at no cost to patients.
We provide an individual care plan developed by a registered nurse and case manager.
Service plan includes medication management, personal care service at home, a Nurse and Case Manager monitoring ongoing needs.
Patient must have Masshealth Standard to qualify.
We accept United, Senior Whole Health, Fallon and Commonwealth Care Alliance.

បើកទទួលចុះឈ្មោះ
ជនមានពិការភាព និងអ្នកជំងឺរ៉ាំរ៉ៃ ដោយឥតគិតថ្លៃ។
យើងផ្ដល់ផែនការថែទាំអ្នកជំងឺជាបុគ្គលដោយគិលានុបដ្ឋាយិកាដែលមានចុះបញ្ជីត្រឹមត្រូវ និងគ្រូពេទ្យគ្រប់គ្រងអ្នកជំងឺ។
ផែនការសេវាកម្មរួមមាន ការគ្រប់គ្រងឱសថ សេវាថែទាំដោយផ្ទាល់តាមផ្ទះ គិលានុបដ្ឋាយិកា
និងគ្រូពេទ្យគ្រប់គ្រងអ្នកជំងឺពិនិត្យតាមដានជាប្រចាំតាមតម្រូវការ។
ដើម្បីមានលក្ខណៈគ្រប់គ្រាន់ អ្នកជំងឺត្រូវតែមាន Masshealth Standard ។
យើងទទួល United, Senior Whole Health, Fallon
និង Commonwealth Care Alliance ។




# គេហដ្ឋានដែលសន្សំសំចៃថាមពល ជិតល្មមនឹងសម្រេចបាន។

ធ្វើឱ្យប្រសើរឡើងនូវផាសុកភាព និងប្រសិទ្ធភាពនៃគេហដ្ឋានរបស់អ្នកជាមួយនឹងការវាយតម្លៃថាមពលក្នុងផ្ទះដោយមិនគិតថ្លៃ។ វាគ្រាន់តែជាវិធីមួយក្នុងចំណោមវិធីជាច្រើនដែលយើងនៅទីនេះ ដើម្បីវាយតម្លៃផ្ទះរបស់អ្នក។

**នេះជារបៀបដំណើរការ៖**

- អ្នកឯកទេសថាមពលនឹងស្វែងរកកន្លែងដែលគេហដ្ឋានរបស់អ្នកអាចនឹងបាត់បង់ថាមពល ជាពិសេសក្នុងអំឡុងពេលខែក្តៅ និងត្រជាក់ខ្លាំង។
- អ្នកឯកទេសអាចដំឡើងឧបករណ៍សន្សំសំចៃថាមពលដោយមិនគិតថ្លៃ និងផ្តល់នូវការកែលម្អប្រព័ន្ធសន្សំសំចៃថាមពលក្នុងផ្ទះ ដូចជាការបញ្ចុះតម្លៃ 75-100% លើការដំឡើងអ៊ីសូឡង់ និងការបិទភ្ជិតខ្យល់ចេញដោយមិនគិតថ្លៃ។
- ពួកគេថែមទាំងអាចពិភាក្សាអំពីការបញ្ចុះតម្លៃ និងការលើកទឹកចិត្តចំពោះឧបករណ៍ដែលមានប្រសិទ្ធភាពថាមពល។

**99% នៃអតិថិជនដែលបានបញ្ចប់ការវាយតម្លៃថាមពលក្នុងផ្ទះនឹងណែនាំវាទៅមិត្តភក្តិ ឬសមាជិកគ្រួសារ។**

nationalgrid

**មោទនភាពជាអ្នកឧបត្ថម្ភរបស់**

mass save

កំណត់ពេលវាយតម្លៃថាមពលក្នុងផ្ទះរបស់អ្នកនៅថ្ងៃនេះ។ ចូលទៅកាន់គេហទំព័រ **ngrid.com/assessment** ឬទូរសព្ទទៅលេខ **1-866-527-SAVE (7283)**

**PRINT READERSHIP**
*50,000 Monthly / 600,000 Annually*
*Plus additional exposure in our online editions at khmerpostusa.com*

KhmerPost USA

**ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM**

# 2024 PRINTING SCHEDULES

## EFFECTIVE JANUARY 1, 2024

## ADVERTISING RATES AND SIZES

*All ads are printed in Full Color*

**Ad Size (WxH)**

| Ad | Size | Price |
|---|---|---|
| **Full Inside** | (10" wide x 13" tall) | $ 552.00 |
| **1/2** | (10" wide x 6.5" tall) | 375.00 |
| **1/4** | (5" wide x 6.5" tall) | 192.00 |
| **1/8** | (5" wide x 3.25" tall) | 108.00 |
| **Business Card** | (3.5" wide x 2" tall) | 60.00 |
| **Full Back Page** | (10" wide x 13" tall) | $ 1000.00 |
| **Front Page 1/2** | (10" wide x 6.5" tall) | 1000.00 |
| **Front Page 1/4** | (5" wide x 6.5" tall) | 620.00 |
| **Front Page 1/8** | (5" wide x 3.25" tall) | 350.00 |
| **Front Page Business Card** | (3.5" wide x 2" tall) | 200.00 |

Your ad is also published in our online editions of the newspaper at khmerpostusa.com




## 2024 PRINTING DATES

***Advertising deadlines are 5 business days prior to printing date.***

| Month | Date | Day |
|---|---|---|
| January | 15 | Monday |
| February | 9 | Friday |
| March | 3 | Sunday |
| April | 1 | Monday |
| May | 1 | Wednesday |
| June | 1 | Saturday |
| July | 1 | Monday |
| August | 1 | Thursday |
| September | 1 | Sunday |
| October | 1 | Tuesday |
| November | 1 | Friday |
| December | 1 | Sunday |

## MONTHLY DISTRIBUTION

*70+ Locations in Lowell, MA • 7,000 copies*
*25 Locations in Lynn & Revere, MA • 1,000 copies*
*25 Locations in Providence & Cranston, RI • 2,000 copies*
*Additional distribution online*

## CONTACT INFO

**Khmer Post USA • P.O. Box 8848 • Lowell, MA 01853**
**Tel: 978.677.7163 • Fax: 978.677.7092**
**Email: khmerpostusa@gmail.com**
**www.khmerpostusa.com**

*Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau*

***Khmer Post USA Distribution Locations Include:***
*Households • Markets • Retail Businesses*
*Restaurants • Office Buildings • Government Offices*
*Chamber of Commerce • Buddhist Temple*
*Laundromats • And Much More*

Follow us @KhmerPostUSA

Subscribe @KhmerPostUSA

Follow us @KhmerPostUSA

# អង្គការសហប្រជាជាតិទាញសញ្ញាអាសន្ន ពីព្រោះឆ្នាំ២០២៣ឈ្នះដាច់ខាងកំដៅ

ដោយ ខ្មែរប៉ុស្តិ៍ស.រ.អា
ឡូវែល ថ្ងៃទី១តុលា២០២៤

អង្គការសិតុណ្ហភាពពិភពលោក(OMM) បានបង្ហាញក្នុងសេចក្តីរាយការថ្មី របស់អង្គការសហប្រជាជាតិ ថ្លែងដោយលោក អង់តូនញ៉ូ គូទ័ររ៉េស ដែលជាអគ្គលេខារបស់អង្គការថា«ឯកទក្កកម្មខាងកំដៅយកបានសំរេចជោគជ័យនៅឆ្នាំ២០២៣នេះ ដោយគេសង្កេតឃើញ ការឡើងកំដៅនៅមហាសមុទ្រ, ការថយទំហំផ្ទាំងសមុទ្រទឹកកក, ឡើងកំដៅលើផ្ទៃដី, ផ្ទៃទឹកសមុទ្រឡើងកំពស់...។ បើតាមលោកអង្គលេខាធិការ យើងកំពុងតែចូលមកដល់កលិយុគនៃ«គ្រោះថ្នាក់ដោយកំដៅពិភពលោកពុំដែលមានពីមុនមកទេ! នេះដោយសារតែការបំពុលអាកាសដោយសារចំហេះប្រេងហ្វូស៊ីល» លោកអង់តូញ៉ូ គូទ័ររ៉េស បន្តរថា«យើងនៅមានពេលបន្តិចដែរ សម្រាប់សង្គ្រោះ







ប្រជាពលរដ្ឋលើលោកនេះ...តែត្រូវផ្តើមធ្វើឥឡូវនេះ»។

កាលពីឆ្នាំមុន មួយភាគបីនៃផ្ទៃសមុទ្រក្នុងពិភាពលោកបានជាប់អន្ទាក់ក្នុងចរន្តនៃកំដៅមហាសាគរ បណ្តាលឲ្យមានការកើនឡើងនូវ ចំនួននឹងកម្លាំងនៃរលកកំដៅក្នុងសមុទ្រ បណ្តាលឲ្យមានការខូចខាត យ៉ាងជ្រាលជ្រៅ ដល់ប្រព័ន្ធបរិដ្ឋានសមុទ្រ ដូចជាផ្កាថ្មជាដើម, កំពស់ទឹកសមុទ្រ ដែលបានឡើងផុតកំពស់នៃឆ្នាំណាៗទាំងអស់ក្នុងពិភពលោកនោះ ក៏បញ្ជូនកំដៅទៅបន្តរការខូចខាតនឹងបន្តរំលាយទឹកកកឥតឈប់ឈរ។

បាតុភូទធម្មជាតិថ្មីៗក្នុងពិភពលោក

-នៅវៀតណាម: ប្រជាជនវៀតណាម នៅហាណូយ នាំគ្នាដើរលុយទឹកត្រឹមដើមទ្រូង នៅពេលដែលទន្លេក្រហមបានជោរជន់ លើសកំពស់ដែលធ្លាប់ជន់តាំងពី២០ឆ្នាំមកហើយ ដោយសារតែខ្យល់ព្យុះ យ៉ាគ្គី ។ នៅតំបន់ជាយក្រុងដែលមានមនុស្សប្រមាណ១៥៣ពាន់នាក់រស់នៅ ក៏រងគ្រោះដោយសារខ្យល់ព្យុះនោះដែរ មាន់ទារាប់លានក្បាល ត្រូវបាត់បង់ ជ្រូក២៥០០ក្បាល មានទាំងគោក្របីក៏ត្រូវខូចខាតដូចគ្នា។ ប្រជាពលរដ្ឋប្រមាណ៥ម៉ឺននាក់ទៀតបានត្រូវជន្លៀស នេះបើតាមសេចក្តីរាយការផ្លូវការវៀតណាម។ ផ្ទះសម្បែងច្រើនខ្នងបានត្រូវបាក់បែក រោងចក្រនានាក៏របើករបាញមិនអាចធ្វើការបាន ស្ពានបានបាក់រលំដោយសារ ខ្យល់ព្យុះ យ៉ាគ្គី ឡើងគោកគាលពីថ្ងៃសៅរមុន។



-នៅប្រទេសថៃ: មនុស្ស៩នាក់បានស្លាប់ នៅក្នុងព្រឹត្តិការរំកិលផែនដីនាតំបន់ខែត្តឈៀងរ៉ៃ កាលពីថ្ងៃសុក្រចុងខែតុលាមុន នេះបើតាមពត៌មានក្រសួងគ្រប់គ្រងគ្រោះមហន្តរាយថៃ, ព្រលានយន្តហោះ ដែលនៅចម្ងាយប្រមាណ១២៥គម បានត្រូវបិទ។ នៅឆ្ងាយបន្តិចផ្នែកខាងជើង នាស្រុកមេសាយ ក្បែរទល់ដែនភូមា ទឹកជំនន់ដ៏ធំមួយ មិនដែលមានតាំងពី៨០ឆ្នាំមកហើយ បានធ្វើឲ្យលិចលង់តំបន់នោះយ៉ាងដំណំ នេះបើតាមមន្ត្រីក្រសួងក្រឡាហោមថៃ សុធីពង្ស ជុលចារ៉ឹម, យោធាថៃបានបញ្ជូនក្រុមជំនួយឧទ្ធម្ភាគចក្រទៅជួយដំបន់នោះ, វត្តអារាមសណ្ឋាគារ បានទទួលគ្រួសារជន្លៀសខ្លួនរាប់ពាន់នាក់។ ក្រុមជំនួយបានប្រើ«Jet Sky»១៦គ្រឿង ទៅជួយរំដោះប្រជាជន នៅកន្លែងដែលមានចរន្តទឹកហូរខ្លាំង។

-នៅប្រទេសភូមា: ទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅទីក្រុង ណៃពិដោ, ទិទំនាបនៃក្រុងថ្មីរបស់របបយោធា នឹងនៅទីក្រុង តុងគូ, ក្រុមអ្នកសង្គ្រោះបានរកឃើញសាកសព៧នាក់នៅក្នុងតំបន់ទឹកលិចនៃភូមិភាគ ម៉ង់ដាឡេ នៃភាគខាងជើង គឺបន្ថែមលើសាកសពដែលរកឃើញ ពីប៉ុន្មានថ្ងៃមុនចំនួន១០នាក់ទៀត នាតំបន់ដដែល។

ក្រុមរដ្ឋបាលយោធាបានរៀបចំតំឡើងជំរុំចំនួន៥០ សម្រាប់ទទួលជនភៀសខ្លួន ដែលមានចំនួនច្រើនពាន់នាក់រងគ្រោះដោយសារទឹកជំនន់នោះ។ កាសែត គ្លោបូលញូឡាយ បានផ្សាយថា ខ្សែផ្លូវដែកដែលផ្ជាប់ទីក្រុង រ៉ង់គូនទៅនឹង ម៉ង់ដាឡេ បានត្រូវផ្តាច់ដោយសារតែទឹកធំនៅតំបន់នោះ។

-នៅប្រទេសកម្ពុជា: ទឹកជំនន់នៃទន្លេមេគង្គ បានធ្វើឲ្យលិចលង់ជាច្រើនខែ នៅតំបន់ជាច្រើននៃប្រទេស ដែលនៅតាមដងទន្លេ គឺដោយសារទឹកដែលជន់ដោយការរលាយទឹកកក នៃខែក្តៅពីតំបន់ភ្នំនៃប្រទេសចិន។ រីឯទឹកជំនន់នៅទីក្រុងភ្នំពេញ នៅបន្តរមិនព្រមស្រកទៅវិញ កាលពីខែសីហាបានបណ្តាលឲ្យខូចខាតផ្ទះសម្បែង នឹងទ្រព្យសម្បត្តិ

**តទៅទំព័រទី១៥**

# បុណ្យភ្ជុំបិណ្ឌនៅឡូវែល

ដោយ ខ្មែរប៉ុស្តិស.រ.អា

ឡូវែល, ថ្ងៃទី៥តុលា២០២៤

តាំងពីជាង២សប្តាហ៍មកហើយ ដែលប្រជាពលរដ្ឋឡូវែលបណ្តាក់គ្នាទៅវត្តនានាដែលនៅជុំវិញក្រុង ដើម្បីប្រគេនចង្ហាន់ហើយឧទ្ទិសផលបុណ្យកុសល ទៅជូនបុព្វបុរស ជីដូនជីតា មាតាបីតា មាមីង ជាអ្នកមានគុណ ក្រែងលោកបានលាចាកលោកនេះទៅហើយ ពុំបានទទួលសម្បត្តិសួគ៌ បែរជាទៅលំបាកវេទនា នាងឋាននរកទៅវិញ នេះជាជំនឿ



ព្រះតេជគុណ មី ខ្សែម ព្រះចៅអធិការ វត្តអង្គរ ឡូវែល

ជាបុណ្យក្នុងសាសនាព្រះពុទ្ធ«ថេរវាទ»ដ៏មានប្រជាប្រិយភាព នៅប្រទេសកម្ពុជា នឹងនៅឡូវែលនេះផងដែរ។

នៅវត្តអារាមប្រមាណ៥ នៃតំបន់ប្តុំក្រុងឡូវែល ដ៏សម្បូរជនជាតិខ្មែររស់នៅ មានវត្ត«ត្រៃរតនារាម»ដែលខ្មែរឡូវែលទៅធ្វើបុណ្យ បានកើតមុនគេឆែមស្វឹត ដោយព្រះគ្រូចៅអធិការ សៅ ឃន, នឹងបន្តរមក មានវត្ត«ពន្លឺពុទ្ធចក្រ»វត្ត«ឡូវែល»នឹងវត្ត«អង្គរ»ដែលឋិតនៅក្នុងឡូវែលតែម្តង, វត្តផ្សេងទៀតក្បែរឡូវែលដែរគឺវត្ត«សាមគ្គី..»ឋិតនៅធីងប៊្ញូរ៍ ។ ព្រះសង្ឃមិនបានអនុញ្ញាត្តិឲ្យចេញទៅក្រៅវត្តនាឱកាសនេះទេគេហៅថា«ចូលវស្សា» គឺលោកត្រូវនៅចាំទទួលគ្រួសារពុទ្ធបរិស័ទ ដែលបានដាក់វេនគ្នា ចំនួន១៥ថ្ងៃ គេហៅថា«កាន់បិណ្ឌ» ដែលលើកគ្នាមកប្រគេងចង្ហាន់ នឹងប្រគេនទេយ្យទាននានា មានស្បង់ចីវរ អង្គរស្បៀង នឹងមានទានធូប ជាបរិក្ខាចាំបាច់គ្រប់យ៉ាងសម្រាប់ព្រះសង្ឃអាចប្រារព្ធពិធីសាសនា នៅក្នុងវត្តនិមួយៗបាន សម្រាប់រយៈពេល១ឆ្នាំទៅមុខ ។ ដូច្នេះនៅថ្ងៃគម្រប់ទី១៥ នៃខែតុលានោះ គេនាំគ្នាប្រារព្ធរួមគ្នាពិធីបុណ្យ«ភ្ជុំបិណ្យ»ពេញមួយថ្ងៃ ។ បន្ទាប់ពីថ្ងៃភ្ជុំនោះទៅ ព្រះសង្ឃត្រូវ




នៅគង់ចាំវស្សាបន្តរ២ខែទៀត ដើម្បីហាត់រៀនធម្មផង នឹងឲ្យពុទ្ធបរិស័ទ រៀបចំដង្ហែរ«កឋិនទាន»ចូលវត្ត ដើម្បីជាការឱបត្ថម្ភសម្ភារ: នឹងបរិក្ខាចាំបាច់ សម្រាប់ព្រះសង្ឃប្រើប្រាស់ក្នុងវត្តផង។

នៅថ្ងៃពិធី«បុណ្យភ្ជុំបិណ្ឌ»នោះ គេឃើញមនុស្សម្នា អ៊ូអរនាំគ្នាទៅវត្ត ដៃមានយួរស្រាក់មានដាក់ម្ហូប មានខ្លួនឈ្មុយឆ្ងាញ់ ជញ្ជូនមកដោយញាតិញោមក្នុងសំលៀកបំពាក់ទំនៀមទំលាប់ខ្មែរដ៏ស្រស់ស្អាត ហើយទទួលយ៉ាងរាក់ទាក់ដោយព្រះសង្ឃ អាចារ្យវត្ត នឹងបាសកជើងវត្ត គេរមែងឮសម្លេងជូនពរ សម្លេងសូត្រធម៌ យ៉ាងរងំ។ បុណ្យភ្ជុំបិណ្ឌនេះ

ព្រះតេជគុណមី ខ្សែម ចៅអធិការវត្តអង្គរ វត្តដែលកើតក្រោយគេ នៅទីដ៏ស្ងប់ស្ងាត់ក្បែរមាត់ទឹកដ៏តូចច្រឡឹងមួយ មានសង្ឃដីការពីពិធិបុណ្យភ្ជុំបិណ្ឌនោះថា«ពុទ្ធបរិស័ទនាំគ្នាយកចង្ហាន់ប្រគេងព្រះសង្ឃនៅថ្ងៃភ្ជុំនោះ ក្នុងបំណង នាំគ្នារំលឹកគុណទៅដល់មាតាបីតា ជីដូនជីតា ដែលបានចែកឋានទៅហើយនោះ... ទាំងអស់គ្នាជឿថាផលបុណ្យដែលកើតពីចិត្តសទ្ធាទាំងឡាយ នឹងបញ្ជូនម្ហូបអាហាដ៏បរិបូណ៌នោះ ទៅដល់មាតាបីតា ឬជីដូនជីតា នឹងបុព្វបុរស់គែបានជាមិនខានឡើយ.... បើតាមអ្នកប្រតិបត្តិវិបស្សនាវិញ ពុំមានជំនឿយ៉ាងជាក់ច្បាស់ថាំបុណ្យកុសលទាំងឡាយនោះ នឹងទៅដល់បុព្វបុរស ឬក៏មិនដល់នោះទេ ដោយហេតុថា ពុំមាននរណាម្នាក់ មានបញ្ញញាណខ្ពង់ខ្ពស់ ក្នុងព្រះពុទ្ធសាសនា ជាអង្គព្រះអរហន្ត ឬក៏អង្គព្រះអរហត្ត នៅឡើយទេ»...នៅលើសំនួរថា មាននរកប្រេត ដែលអាចជាបុព្វបុរសនៃពុទ្ធបរិស័ទ មកស៊ីបាយបោះ នៅពេលភ្ជុំបិណ្យ នោះជាអ្វីទៅ? ព្រះតេជគុណមី ខ្សែម តបថា«នោះ ជាមនុស្សគេអាចមើលឃើញ រីឯអមនុស្ស យើងមើលមិនឃើញទេ យើងក៏មិនអាចនិយាយថាមាន អមនុស្ស មកទទួលបាយបោះ




យើងបានដែរ ទានទាំងឡាយដែលពុទ្ធបរិស័ទធ្វើទៅហើយ រមែងបានទៅដល់ញាតិ បើមិនឆ្ងាយក៏ជិតដែរ បើមិនបានមួយក៏បានទៅដល់មួយទៀត ពីព្រោះញាតិដែលបាត់បង់ជីវិតទៅហើយនោះ មានចំនួនច្រើនអាណែកកប្បកា»



ជប់លៀងរាំកំសាន្តថ្ងៃភ្ជុំបិណ្ឌនៅឡូវែល

។ សំនួរជាបន្តរស្តីពី ទស្សនៈប្រេត នឹងបីសាចមានប្រទេសខ្លះដែលកាន់សាសនា

**តទៅទំព័រទី២២**

# បោះឆ្នោតប្រធានាធិបតីអាមេរិកាំង៖ រឿងបែកធ្លាយអាចកំបាំងនៅខែតុលា

ដោយ ខ្មែរប៉ុស្តិ៍ស.រ.អា

ឡូវែល ថ្ងៃទី ៩ ខែ តុលា ឆ្នាំ២០២៤

នៅរាល់ខែតុលាមុនឱកាសបោះឆ្នោតប្រធានាធិបតីអាមេរិកាំងម្តងៗអ្នកបោះឆ្នោតតែងតែមានការរារែក ហើយក៏ប្តូរសេចក្តីសម្រេច ប្តូរយកបេក្ខជនថ្មីរបស់ខ្លួនជាជិត ឬក៏ទី ៣ ព្រឹត្តិការនៃចៃដន្យជាតិដូចជាគ្រោះធម្មជាតិ ជម្ងឺរាតត្បាត ឬក៏ការស៊ើបអង្កេតបទឧក្រឹដ្ឋជាដើម» ។ ក្នុងចំណោមរឿង«អាថិកំបាំងនៃខែតុលា» មានមួយដែលគួរចាប់អារម្មណ៍ខ្លាំង គឺការប្រជែងរវាង ហ៊ីឡារី គ្លីងតុន ជាមួយនឹង



ពត៌មានមួយថា«លោក ប៊ូស បានត្រូវប៉ូលិសចាប់ខ្លួន ពីបទបើកបររថយន្តពេលកំពុងស្រវឹងស្រាឆ្នាំ១៩៧០» រឿងនោះបានត្រូវបន្សាបទៅវិញដោយ ធ្វើឲ្យក្លាយទៅជាគំនុំផ្ទាល់ខ្លួនធម្មតា នៅពេលបោះឆ្នោតប្រធានាធិបតី បាន។

នៅឆ្នាំ១៩៨០ បេក្ខជនប្រធានាធិបតី រ៉ូណាលរ៉េគ្កាន់ហ៊ានរហូតដល់ប្រកាសប្រាប់អ្នកគាំទ្រខ្លួនថា គូរបដិបក្ខរបស់ខ្លួនគឺលោក ជីមី ខទ័រ ខាងគណបក្សប្រជាធិបតេយ្យ«លបធ្វើការចរចារសម្ងាត់ជាមួយភេរវករ ដើម្បីរំដោះចំណាប់ខ្មាំងអាមេរីកាំង៥២នាក់ ចេញពីអ៊ីរ៉ង់ .. ដោយហេតុតែចង់ឈ្នះឆ្នោត» តែជោកជ័យនៃកិច្ចចរចានោះ មកដល់យឺតពេលក្រោយថ្ងៃបោះឆ្នោត ចំណាប់ខ្មាំងអាមេរីកាំងបានត្រឡប់មកប្រទេសនៅថ្ងៃ២០មករា១៩៨១ ទៅជាជោកជ័យរបស់ រ៉ូណាល រ៉េគ្កាន់ នៅថ្ងៃប្រកាសឡើងជាប្រធានាធិបតី ទៅវិញ។

បើសម្រាប់ អូស្កា វិនបើក ជាអ្នកឯកទេសនយោបាយអាមេរិកាំង លោកយល់ថាព្រឹទ្ធិការបែកធ្លាយអាទិកំបាំងខែតុលា ដោយសារតែកើតមានច្រើនពេកទៅក៏ក្រុមអ្នកឃោសនា ត្រៀមយុទ្ធនាការការពារទុកមុន គេរៀបប្រព័ន្ធគ្រប់គ្រងវិបត្តិខែតុលាដែលអាចកើតឡើង

ញ៉ើកញយ ដោយសារមានការធ្លាយអាថកំបាំង បានត្រូវផ្ទុះឡើង។

ថ្វីត្បិតតែ បេក្ខនារីប្រធានាធីបតីអាមេរីកាំង កាម៉ាឡា ហារីស មានសន្ទុះស្ទីតិលើសលោក ឌណាល ត្រាំ បានខ្លះហើយក្តី(លើស៧ពិន្ទុ) ក៏ការប្រកួតគ្នានាខែតុលានេះ នៅមានឱកាសដ៏ប្រកបដោយអាថកំបាំងមិនទាន់យកជាការបាន ពីព្រោះច្រើនដងមកហើយ ដែលបេក្ខជនប្រធានាធីបតីដ៏មានសង្ឃឹម ថានឹងបានជាប់ចូលសេដ្ឋវិមាន ក៏ស្រាប់តែបែរជាធ្លាក់ប្រជាប្រីយភាព ដោយឥតគ្រោងទុក ទៅជាចាញ់វិញបាន តែក្នុងមួយប៉ប្រិចភ្នែក មុនពេលបោះឆ្នោត។ តាំងពី៥០ឆ្នាំមកហើយដែល«អាថកំបាំងនៃខែតុលា» បានប្តូរដំណើពីក្តីសង្ឃឹមរបស់អ្នកដែលបំរុងនឹងឈ្នះ បានច្រើនគ្នាទៅហើយ។

មានរឿងប្លែកៗដែលកើតស្មានមិនដល់, បានត្រូវ អូស្កា វីនបើក(Oscar Winberg)អ្នកប្រវត្តិវិទូនិយាយថា«រឿងចម្លែកនោះមាន៣ប្រភេទគឺ ១ ព្រឹត្តិការនយោបាយការទូត ដែលកើតទាន់ហាន់ចំពោះសហរដ្ឋអាមេរិកនៅលើឆាកអន្តរជាតិ ២ រឿងអាស្រូវនយោបាយ នៃអតីតកាលបានផ្ទុះឡើងវិញ ដោយការលាក់មិន

ឌណាល ត្រាំ កើតឡើងនៅឆ្នាំ២០១៦ គឺនៅឆ្នាំ១៩៩៥ ឌណាលត្រាំបានប្រកាសខាតបង់ប្រាក់៩០០លានដុល្លា ដែលធ្វើឲ្យលោកគេចរួចពីការបង់ពន្ធជូនរដ្ឋប្រមាណរាប់សិបឆ្នាំចុងក្រោយនេះ... ចំណែកឯ ហ៊ីឡារី គ្លីងតុន វិញបែកធ្លាយរឿង«លោកស្រីបានបញ្ជូនសារផ្លូវការតាមបណ្តាញឯកជនខុសច្បាប់ផ្ទាល់ខ្លួនរបស់លោកស្រី»ដែរ។



ប៉ុន្តែក៏មានករណីបែកធ្លាយអាថិកំបាំងខ្លះទៀត ក៏មិនមានឥទ្ធិពលអ្វីខ្លាំងលើលទ្ធផលឆ្នោតដែរ ដូចជា ជ័ចឌុបិលយូ ប៊ូស ជាបេក្ខជនខាងបក្សសាធារណរដ្ឋ នាឆ្នាំ២០០០មានការធ្លាយ

ដោយចៃដន្យ ពេលណាមួយ, ក្រុមនោះមានទាំងសើរើកកាយ សិក្សារកអាថកំបាំង ដែលអាចកើតមាន ដើម្បីបំបែរឲ្យបានជាប្រយោជន៍សម្រាប់ខ្លួនឯងវិញផង។ ដូច្នេះ ក្នុងនយោបាយអាមេរីកាំង

គេចំណាយលុយនឹងពេលវេលាដ៏សន្ធឹកសន្ធាប់ ដើម្បីជីករកអាថកំបាំងក្រខ្វក់របស់គូរប្រជែងខ្លួន មិនតែប៉ុណ្ណោះ គេថែមទាំងជួលឲ្យមានអ្នកស៊ើបអង្កេត ពីបេក្ខជនខ្លួនឯងផងដែរ ក្រែងមានចន្លោះអាថកំបាំងណាមួយ ដែលក្រុមខ្លួនមិនបានត្រៀមទប់ទល់... ប៉ុន្តែករណីចុងក្រោយនេះ ក៏គ្រោះថ្នាក់ណាស់ដែរ បើដំណឹងនេះបែកធ្លាយដល់សាធារណជន។

ថ្វីត្បិតតែវិបត្តិ«បែកធ្លាយអាថកំបាំងខែតុលា»ជាច្រើន បានកើតជាធម្មតា ដោយសារតែមានការលូកដៃពីបរទេសក្នុងការបោះឆ្នោត ក្នុងបណ្តាញឃោសនាបំភ្លៃការពិត អូស្កា វិនបើក បន្ថែមថា«វាមានឥទ្ធិពលការតែខ្សោយទៅហើយមិនដូចពេលមុនទេ នេះក៏ដោយសារតែអ្នកដែលមិនទាន់សម្រេចចិត្ត កាន់តែមានចំនួន តិចតួចទៅៗ... ឥឡូវនេះពលរដ្ឋអាមេរីកាំង ច្រើន«បោះឆ្នោតភក្តី»ឲ្យគណបក្សណាដែលខ្លួនធ្លាប់ប្រកាន់យក។ នៅក្នុងប្រព័ន្ធបោះឆ្នោតសហរដ្ឋអាមេរីក ដែលមានគណបក្សធំ២ ប្រជែងគ្នា គេសង្កេតឃើញគណបក្សនិមួយៗ មានអ្នកគាំទ្ររបស់ខ្លួន ពី៤៥ទៅ៤៧%ទៅហើយ ដូច្នេះនៅសល់ អ្នកបោះឆ្នោតតិចតួចណាស់ដែលត្រូវទាក់ទាញឲ្យបាន តែក៏បានន័យថា«ភាគតិចនោះហើយ ដែលនឹងធ្វើឲ្យសម្រេច មានគម្លាតពីគ្នាពីគូរប្រកួតទាំង២»។

អូស្កាវិនបើករំលឹកបន្ថែមថា«ពលរដ្ឋអាមេរីកាំងឥឡូវ ប្តើមបោះឆ្នោតមុនថ្ងៃកំណត់តាមរយប្រអប់សំបុត្រ»ចលនាថ្មីនេះ បានចាប់កំណើតនៅពេលមានជម្ងឺរាតត្បាត«Covid-19» បានន័យថា ពត៌មានថ្មីៗដែលអាចនឹងបណ្តាលឲ្យមានការផ្លាស់ប្តូរចិត្តអ្នកបោះឆ្នោត បានត្រូវបង្ហាញថា«មានផលវិបាកលើសម្លេងឆ្នោត តិចជាងកាលពីអតីតកាល»។

ដំណាក់ការឃោសនា នៅផ្លូវត្រង់ចុងក្រោយរបស់ ត្រាំ នឹង ហារីស

គ្មានអ្វីអាចឲ្យខុសខូចខាតទៀតទេ! លីស ជាកូនស្រីអតីតអនុប្រធានាធិបតី ឌីក ឆេណេ ខាងគណបក្សសាធារណរដ្ឋ បានចេញមុខឃោសនានៅរដ្ឋ វីកុងសីង នឹងបោះឆ្នោទជាលើកដំបូងឲ្យ កាម៉ាឡា ហារីស ខាងគណបក្រ្សជាធិបតេយ្យ ជាគូរប្រជែង ក្នុងនាមជាស្រ្តីអាមេរីកាំងចរន្តជឿនលឿន មិនមែនស្តាំផុតនិយមទេ, រីឯ អេលុនមុក មហាសេដ្ឋីលំដាប់កំពូលពិភពលោកវិញ បានចេញមុខមក

តទៅទំព័រទី១៨

តមកពីទំព័រទី ០១

# តារា ហុង ឈ្នះឆ្នោតជុំទី១ សម្រាប់

ឲ្យចេញទៅបោះ ខ្ញុំក៏បានចំនួនអ្នកចេញទៅបោះឆ្នោតកើនឡើងជាង៣០០សម្លេង ដែលជាហេតុធ្វើឲ្យខ្ញុំបានសម្លេងឈ្នះលើពូ រ៉ាឌី ម៉ម ចំនួន១៨២សម្លេង...

**សំនួរៈ តើលោកមានដឹងទេថា អ្នកបោះឆ្នោតគេផ្លាស់ប្តូរចិត្ត លែងចង់បោះឆ្នោតឲ្យ រ៉ាឌី ម៉ម ឬក៏មនុស្សថ្មីទើបនឹងចេញមក?**

តារា ហុងៈ មានខ្លះគេក៏ប្តូរចិត្តដែរ តែដោយសារខ្ញុំទៅគោះទ្វារតាមផ្ទះ បាននិយាយជាមួយម្ចាស់ឆ្នោត ដោយចំពោះមុខ សុំឲ្យគេផ្តល់ឱកាសឲ្យខ្ញុំបានបំរើសហគមន៍យើង ថាតើអ្វីទៅដែលសំខាន់សម្រាប់សង្កាត់១៨យើង តើវិស័យអប់រំ នឹងវិស័យអាចទិញផ្ទះក្នុងតម្លៃថោក ពលរដ្ឋយល់យ៉ាងណា? គឺជាឪកាសដ៏ល្អសម្រាប់ពន្យល់អ្នកបោះឆ្នោត ឲ្យចង់មានការផ្លាស់ប្តូរ ដែលអាចឲ្យខ្ញុំបំរើដោយគ្មានល្បិចបាន ហេតុនោះហើយបានជាមានមនុស្សចេញមកបោះឆ្នោតច្រើន

**សំនួរៈ ក្នុងករណីដែលលោក តារា ហុង ឈ្នះឆ្នោតលើបេក្ខជនឯករាជ្យ ដេវ អារឡេត នៅថ្ងៃទី៥វិច្ឆិកាខាងមុខ តើលោកមានគម្រោងទៅភ្នំពេញ ទៅសុំឪវាទពីនាយករដ្ឋមន្ត្រីខ្មែរដែរឬទេ? ដោយហេតុថា មានបេក្ខជនមុនៗបានធ្វើយ៉ាងនោះ នៅពេលជាប់ឆ្នោតជាសមាជិសភាភ្លាមមក**

តារា ហុងៈ ខ្ញុំមិនមានគម្រោងទៅសុំឪវាតពិលោក ហ៊ុន សែន ឬអ្នកធំៗនៅកម្ពុជាអីទេ ខ្ញុំយល់ថា បើចង់ឲ្យមានការរីកចំរើនក្នុងតំបន់១៨យើង គឺយើងត្រូវនិយាយជាមួយពលរដ្ឋក្នុងសង្កាត់យើង ស្វែងរកជាមួយគ្នានូវការរីកចំរើនជាមួយគ្នា...

**សំនួរៈ នៅក្នុងគំរូនៃនយោបាយរបស់ តារា ហុង ខ្លួនឯង សម្រាប់សហគមន៍ខ្មែរ តើមានគំរូណាមួយដែល តារា យល់ថាអាចយកមកពីកម្ពុជា មកប្រើបាននៅសហរដ្ឋនេះដែរឬទេ?**

តារា ហុងៈ អត់មានទេ ហើយក៏មិនចូលចិត្តដែរ!... ខ្ញុំមកដល់សហរដ្ឋ

តទៅទំព័រទី១៩

# Dara Hong Wins First Round of Massachusetts Representative in 18th District

From Page 02

voters that there is a change that allows me to be a service provider without trickery, that was why so many people come out to vote for me.

Question: If Dara Hong wins the election of independent candidate Dave Ouellette on November 5, do you plan to go to Phnom Penh to seek advice from the Prime Minister of Cambodia? Because previous candidates did so immediately after being elected to the National Assembly.

Dara Hong: I have no plans to seek advice from Hun Sen or high-ranking people in Cambodia. I understand that if we want to make progress in our 18th District, we need to talk to the people in our neighborhood, find common ground together ...

Question: In Dara Hong's own political model for the Cambodian community, is there any model that Dara thinks can be used from Cambodia in the United States?

Dara Hong: No, I do not like it either! ... I came to the United States in 2013 at the age of 13, did not remember politics in Cambodia, I studied at the “Middlesex School”, learned politics from American culture, from the values of the American people, from freedom to democracy ... I do not know much about politics in Cambodia ... but I have heard from many Cambodians that they want to see a change in politics related to Cambodia. Rady Mam also see that his politics are no longer effective ... They want to see a new generation with new energy, new ideas to lead new politics in the region, because the time has come for a new generation.

Question: Do you want to see the new generation take turns with new ideas, new energy for the betterment of society. Did Radim Mam express his surrender to the winner, which is the electoral culture?

Dara Hong: He called to "wish" me the next day but has not met in person yet!

Question: On November 5, there will be an election for the President of the United States, and Dara Hong, a Democrat like Camala Harris, we will see how much Lowell, where many Cambodian Americans live, will do towards that important election?

Dara Hong: I believe that the Cambodian people in Lowell will go to the polls in large numbers. I, a member of the Democratic Party, will support the candidacy of Vice President Kamala Harris and Governor Tim Wales for the presidency competing with Donald Trump on the Republican side. I call on all people to go to the polls on November 5, 2024, to fulfill their



តមកពីទំព័រទី ០១

## លទ្ធផលចម្លែកនៃការបោះឆ្នោត...

ហើយ ថ្វីត្បិតតែនៅមានរដ្ឋ៩ទៀត មិនទាន់រាប់សន្លឹកឆ្នោត មិនទាន់ចប់ក៏ដោយក្តី។ លោកស្រីអនុប្រធានាធិបតី កាម៉ាឡា ហារីស ក៏បានទូរស័ព្ទទៅជូនពរលោក ត្រាំ តាមប្រពៃណី នៅរសៀលទី៦នោះរួចហើយ។ លោក ឧណាល ត្រាំ ជាជនជាប់ពិរុទ្ធ៣៤ករណី សារភាពរួចហើយ នៅតុលាការព្រហ្មទណ្ឌ បានជាប់ឆ្នោតជាប្រធានាធិបតី កាលពីថ្ងៃទី៥វិច្ឆិកា២០២៤ តែតុលាការនឹងប្រកាសទោស នៅថ្ងៃទី២៦វិច្ឆិកាខាងមុខ នេះជាព្រឹត្តិការចម្លែកមិនដែលមានពីមុនមកទេ។

នៅពេលចេញអត្ថបទនេះ លោក ឧណាលត្រាំបានឈ្នះនៅរដ្ឋភាគកណ្តាលនៃប្រទេស ពីខាងជើងដល់ត្បូង រីឯរដ្ឋដែលជា«រដ្ឋងាករេ» ក៏ ត្រាំ យកបានរដ្ឋច្រើនទៀត ដូចជា រដ្ឋផ្លរីដា រដ្ឋភេនស៊ីវេនា រដ្ឋជីរចា រដ្ឋផ្នែកខាងត្បូងទាំងអស់ សុម្បីតែរដ្ឋដែល ត្រាំ តិះដៀលថា មានជនជាតិខ្លះស៊ីឆ្កែ ស៊ីឆ្មារបស់អ្នកជិតខាង ក៏ធ្លាក់ក្នុងដៃលោកត្រាំ ដែរ... ត្រាំ ឈ្នះ ទាំងមានរដ្ឋខ្លះ នៅមិនទាន់បានលទ្ធផលបញ្ចប់ នៅឡើយផង។

ងាកត្រឡប់ទៅរកភាពជឿជាក់ថា បេក្ខនារី កាម៉ាឡា ហារីស អាចនឹងក្លាយជាប្រធានាធិបតីទីមួយ ដែលជាស្រ្តីភាទ គឺមានអតីតប្រធានាធិបតីដែលនៅរស់ទាំង៥រូប បានសម្តែងករគាំទ្រដល់បេក្ខនារី គណបក្សប្រជាធិបតេយ រួមទាំងវរជនគណបក្សសាធារណរដ្ឋរបស់ត្រាំ ជាង២០០រូបទៀត បូករួមទាំងតារា ល្បីឈ្មោះកំពូលច្រើនរូប ក៏មកគាំទ្រ កាម៉ាឡា ដែរ ទាំងនោះជារឿងដែលគេស្មានមិនដល់ថា មនុស្សដ៏ឆ្នើមទាំងនោះ ហេតុអ្វីក៏គ្មាន«ទឹកមាត់ប្រៃ»អ្វីបន្តិចសោះ យ៉ាងដូច្នោះ?

ឆ្លងកាត់ការបោះឆ្នោតជាមួយបេក្ខជនប្រធានាធិបតី ភេទស្រី ជាលើកទី២ហើយ, ជោគជ័យរបស់ ឧណាល ត្រាំ លើកនេះ ហាក់ដូចជាមិនខុសអ្វី៨ឆ្នាំមុន នៅពេលដែល ត្រាំ ប្រកួតនឹង លោកស្រី ហ៊ីឡារី គ្លីងតុន នៅឆ្នាំ២០១៦, ពេលនោះ ហ៊ីឡារី មានប្រៀបជាង ត្រាំ ច្រើនគួរឲ្យសង្ឃឹមថានឹងឈ្នះបាន ប៉ុន្តែស្រាប់តែស្អែកឡើង លទ្ធផលបែរជាផ្ទុយបញ្ច្រាសទីស ទៅជា ត្រាំ អ្នកឈ្នះទៅវិញ។ តើស្ត្រីភេទអាមេរីកាំង នៅតែជា«ភេទទន់ខ្សោយ»ពុំអាចក្លាយទៅជាប្រធានាធិបតីបាននៅឡើយ? ឬក៏នៅមានអាថិកំបាំងអ្វីផ្សេងទៀត ដែលគេមិនបានដឹង?



ផែនទីនយោបាយថ្មីរបស់ស.រ.អា៖ ពណ៌ក្រហមជារដ្ឋដែល ឧណាល ត្រាំ ឈ្នះ, ពណ៌ខៀវ ជារដ្ឋដែល ហារីស ឈ្នះ







# កម្ពុជាជាប់លេខជិតចុងបំផុតខាងនីតិរដ្ឋ តាមការស្រាវជ្រាវអង្គការគម្រោងយុត្តិធម៌ពិភពលោកឆ្នាំ២០២៤

ដោយ ឌី ខេមបូឌា ដេលី

ប្រទេសកម្ពុជា ជាប់ចំណាត់ថ្នាក់លេខ១ ជាប្រទេសដែលមាននីតិរដ្ឋខ្សោយបំផុតក្នុងចំណោមប្រទេសជាសមាជិកអាស៊ានទាំង១១ ដែលស្ថិតក្នុងលេខរៀងទី១៤១ ក្នុងចំណោមប្រទេសទាំង១៤២ នៅលើពិភពលោកសម្រាប់ឆ្នាំ២០២៤។

អង្គការគម្រោងយុត្តិធម៌ពិភពលោក (World Justice Project (WJP))បានចេញផ្សាយសេចក្តីរាយការណ៍ស្តីពីនីតិរដ្ឋនៃប្រទេសទាំង ១៤២ នៅលើពិភពលោក កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០២៤នេះថាប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខរៀងទី១៤១ ចំណែកប្រទេសភូមាជាប់ចំណាត់ថ្នាក់លេខរៀងទី១៣៨ ខណៈប្រទេសហ្វីលីពីន ជាប់ចំណាត់ថ្នាក់លេខរៀងទី ៩៩ និងប្រទេសវៀតណាម ជាប់ចំណាត់ថ្នាក់លេខរៀងទី៨១។

ក្រៅពីនេះប្រទេសថៃជាប់ចំណាត់ថ្នាក់លេខរៀងទី៧៨ ខណៈប្រទេសឥណ្ឌូនេស៊ី ជាប់ចំណាត់ថ្នាក់លេខរៀងទី៦៨ ចំណែកប្រទេសម៉ាឡេស៊ីជាប់ចំណាត់ថ្នាក់លេខរៀងទី៥៥។

ដោយឡែកប្រទេសសិង្ហបុរី មាននីតិរដ្ឋល្អជាងគេ គឺជាប់ចំណាត់ថ្នាក់លេខរៀងទី១៦ រីឯប្រទេសឡាវ ប្រទេសទីម័រលេស និងប្រទេសប្រ៊ុយណេដារ៉ូសាឡាម មិនត្រូវបានរាប់បញ្ចូលក្នុងសេចក្តីរាយការណ៍នេះទេសម្រាប់ឆ្នាំ ២០២៤ នេះ។

ការកំណត់នីតិរដ្ឋនៃអង្គការគម្រោងយុត្តិធម៌ពិភពលោក គឺផ្អែកលើមូលដ្ឋានពីវិសាលភាពនៃការប្រើអំណាចដោយមេដឹកនាំប្រទេសនីមួយៗជុំវិញការធានានូវការអនុវត្តរដ្ឋធម្មនុញ្ញ ការអនុវត្តច្បាប់ផ្សេងៗ រួមទាំងការធានានូវសេរីភាពសារព័ត៌មានផងដែរ។ ដទៃពីនេះ ក៏វាស់វែងទៅលើការប្រព្រឹត្តអំពើពុករលួយ ការបើកចំហសេរីភាពពីរដ្ឋាភិបាល ការបើកចំហសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ ការធានាបាននូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងកត្តាមួយចំនួនទៀត។

ចាប់តាំងពីឆ្នាំ២០១៦ មក ប្រទេសកម្ពុជាតែងរក្សាតំណែងជាប្រទេសដែលមាននីតិរដ្ឋទន់ខ្សោយក្នុងចំណាត់ថ្នាក់លេខ២ នៅលើពិភពលោករហូតមកគ្រាន់តែខុសលេខរៀងទៅតាមចំនួនប្រទេសដែលគម្រោងយុត្តិធម៌ពិភពលោកបានកំណត់ក្នុងការស្រាវជ្រាវទៅតាមឆ្នាំនីមួយៗប៉ុណ្ណោះ។




ជាក់ស្តែង ឆ្នាំ២០១៦ ឆ្នាំ២០១៧ និងឆ្នាំ២០១៨ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខរៀងទី១១២ ចំនួន ៣ ឆ្នាំជាបន្តបន្ទាប់គ្នា ក្នុងចំណោមប្រទេស ១១៣។ ឆ្នាំ២០១៩ ជាប់ចំណាត់ថ្នាក់លេខរៀងទី១២៥ ក្នុងចំណោមប្រទេស ១២៦។ឆ្នាំ២០២០ កម្ពុជាជាប់ចំណាត់ថ្នាក់លេខរៀងទី១២៧ ក្នុងចំណោមប្រទេស ១២៨។

នៅឆ្នាំ២០២១ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខរៀងទី១៣៨ ក្នុងចំណោមប្រទេស១៣៩។ ឆ្នាំ២០២២ កម្ពុជាជាប់ចំណាត់ថ្នាក់លេខរៀងទី ១៣៩ ក្នុងចំណោមប្រទេស១៤០។ ដោយឡែកឆ្នាំ២០២៣ និងឆ្នាំ២០២៤ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខរៀងទី១៤១ ចំនួន ២ឆ្នាំជាប់ៗគ្នា ក្នុងចំណោមប្រទេស១៤២ ខណៈប្រទេសដែលមានពិន្ទុក្រោមកម្ពុជារហូតមកនោះ គឺគ្មានប្រទេសណាផ្សេងក្រៅពីប្រទេសវេណេហ្ស៊ុយអេឡា នៅអាមេរិកខាងត្បូងនោះឡើយ។

ជុំវិញបញ្ហានេះ អតីតនាយកខុទ្ទកាល័យប្រធានគណបក្សសង្គ្រោះជាតិ លោក មុត ចន្ថា សរសេរលើគណនីហ្វេសប៊ុករបស់ខ្លួនកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤ បែបឌឺដងថា លោកសូមអបអរសាទរកម្ពុជាដែលជាប់ចំណាត់ថ្នាក់លេខ១៤១ ដែលមាន "នីតិរដ្ឋបាតតារាង" ក្នុងចំណោមប្រទេសចំនួន ១៤២ សម្រាប់ឆ្នាំ២០២៤ នេះ។

ក្រុមអ្នកសង្កេតការណ៍រិះគន់ថា កម្ពុជាស្ថិតក្រោមការដឹកនាំជាង ៤០ឆ្នាំ របស់បក្សកាន់អំណាច លោក ហ៊ុន សែន បានប្រើអំណាចយោធាផ្តាច់មុខរំលោភលើច្បាប់អន្តរជាតិនានាយ៉ាងធ្ងន់ធ្ងរ ដូចជា កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងរដ្ឋធម្មនុញ្ញ ជាដើម ដែលជាហេតុធ្វើឱ្យនីតិរដ្ឋរបស់កម្ពុជាមិនអាចចេញផុតពីបាតតារាងបែបនេះ៕

# Cambodia Ranked Bottom of List on the Rule of Law, According to World Justice Project 2024 Report

Cambodia ranks 141st on the rule of law among 142 countries in the world, released by the World Justice Project (WJP) on October 24, 2024.

Cambodia ranks first as the country with the weakest rule of law among the 11 ASEAN member countries, ranking 141st out of 142 countries in the world for 2024.

The World Justice Project (WJP) released a report on the rule of law of 142 countries on October 24, 2024: Cambodia ranks 141st, Burma ranked 138th, The Philippines ranked 99th and Vietnam ranked 81st. Thailand is ranked 78th, followed by Indonesia at 68th and Malaysia at 55th.

Singapore has the best rule of law at 16th, while Laos, Timor-Leste and Brunei Darussalam are not included in the report for 2024.

The definition of the rule of law of the World Justice Project is based on the scope of power exercised by the leaders of each country around ensuring the implementation of the constitution, the implementation of various laws, and the guarantee of freedom of the press. It also measures corruption, openness to freedom from government, openness to basic citizens' rights, security, public order, and more.

Since 2016, Cambodia has maintained its position as the second weakest country under the rule of law in the world, only outnumbered by the number of countries the World Justice Project has identified in its annual research.

In fact, in 2016, 2017 and 2018, Cambodia was ranked 112 for 3 consecutive years out of 113 countries. In 2019, it was ranked 125th out of 126 countries. By 2020, Cambodia ranks 127th out of 128 countries.

In 2021, Cambodia ranks 138th out of 139 countries. In 2022, Cambodia ranks 139th out of 140 countries.

In 2023 and 2024, Cambodia ranked 141st for two consecutive years out of 142 countries, while the country that has scored below Cambodia so far is none other than Venezuela in South America.

On this issue, former Chief of Staff of the President of the National Rescue Party, Mr. Muth Chantha, wrote on his Facebook account on October 24, 2024 in a way of mocking that he would like to congratulate Cambodia, which ranks 141st with the "rule of law at the bottom of the table" among 142 countries for 2024. Observers criticize Cambodia for more than 40 years under the ruling party Hun Sen's use of monopoly military power to seriously violate international law such as the Paris Peace Agreement and the Constitution, which makes it impossible for Cambodia's rule of law to get out of the bottom of such a list.

# អតីតមេបក្សជំទាស់ជំរុញឱ្យមានចលនាតស៊ូប្រឆាំង ដើម្បីផ្លាស់ប្តូរការគ្រប់គ្រងនៃរបបត្រកូលហ៊ុន

ដោយ ឌី ខេមបូឌា ដេលី

អតីតមេដឹកនាំបក្សប្រឆាំង លោក សម រង្ស៊ី ជំរុញឱ្យមានការរៀបចំចលនាតស៊ូមួយដើម្បីផ្លាស់ប្តូររដ្ឋាភិបាលក្រុមគ្រួសារត្រកូល ហ៊ុន ដែលកំពុងដឹកនាំប្រទេសកម្ពុជាតាមរបបផ្តាច់ការ ពុករលួយ និងក្បត់ជាតិខ្មែរ។

អតីតប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី សរសេរលើទំព័រហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី២៥ តុលា នេះថា ប្រជាពលរដ្ឋខ្មែរត្រូវតែផ្លាស់ប្តូររបបផ្តាច់ការ ពុករលួយ និងក្បត់ជាតិ ដែលកំពុងដឹកនាំដោយក្រុមគ្រួសារត្រកូលហ៊ុនរបស់លោក ហ៊ុន សែន ជាង ៤០ ឆ្នាំមកនេះ។

លោកថា ចលនាតស៊ូនេះត្រូវតែបង្ខំឲ្យរបបដឹកនាំដែលកំពុងគ្រប់គ្រងដោយលោក ហ៊ុន សែន រៀបចំឱ្យមានការបោះឆ្នោតពិតប្រាកដ ត្រឹមត្រូវ ដោយមានការឃ្លាំមើលពីសហគមន៍អន្តរជាតិតាមរយៈអង្គការសហប្រជាជាតិជាដើម។

លោកបន្តថា ឱ្យតែមានការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ របបផ្តាច់ការនឹងមិនអាចក្តោបក្តាប់អំណាចតទៅទៀតបានឡើយ គឺមានន័យថានឹងត្រូវធ្លាក់ពីតំណែងមួយរំពេច។

លោក សម រង្ស៊ី លើកឡើងថា ពលរដ្ឋខ្មែរគ្រប់គ្នាដែលស្រឡាញ់សេរីភាព និងយុត្តិធម៌ ត្រូវយល់ថារបបដែលកំពុងគ្រប់គ្រងដោយលោក ហ៊ុន សែន នឹងមិនរៀបចំឱ្យប្រទេសកម្ពុជាមានការបោះឆ្នោតមួយដែលប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌បានទេ ដែលទង្វើបែបនេះគឺផ្ទុយពីខ្លឹមសារដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសទាំងស្រុង។

អតីតមេដឹកនាំប្រឆាំងរូបនេះអះអាងថា ពលរដ្ឋខ្មែរមិនត្រូវរង់ចាំការបោះឆ្នោតដែលរៀបចំដោយរដ្ឋអំណាចសព្វថ្ងៃនេះទេ ព្រោះថារាល់ការបោះឆ្នោតម្តងៗដែលរៀបចំដោយរបបលោក ហ៊ុន សែន សុទ្ធតែជាការបោះឆ្នោតក្លែងបន្លំ និងរំលោភឆន្ទៈប្រជារាស្ត្រខ្មែរតែប៉ុណ្ណោះ។

អ្នកវិភាគនយោបាយ និងជាប្រធានវេទិកាពលរដ្ឋ លោក គឹម សុខ ប្រាប់សារព័ត៌មាន The Cambodia Daily នៅថ្ងៃទី២៥ តុលា នេះថា ប្រព័ន្ធដឹកនាំកុម្មុយនីស្តត្រកូលហ៊ុននៅប្រទេសកម្ពុជាគឺស្ថិតនៅក្រោមអំណាចផ្តាច់ការអាជ្ញាទំនើងចិត្តរបស់បុគ្គលតែម្នាក់គត់ គឺលោកហ៊ុនសែន។

លោកថាលោក ហ៊ុន សែន គឺជាមនុស្សដែលមានគោលការណ៍អាត្មានិយមដឹកនាំដើម្បី តែ ផល ប្រយោជន៍អំណាចគ្រួសារហ៊ុនតែមួយមុខប៉ុណ្ណោះ ដោយមិនខ្វល់ពីគ្រោះមហន្តរាយចំពោះប្រទេសជាតិឡើយ។

លោកគឹមសុខ បញ្ជាក់ថា លោក ហ៊ុនម៉ាណែតដែលជានាយករដ្ឋមន្ត្រីសព្វថ្ងៃនេះ គ្រាន់តែជាជំនួយការឲ្យលោក ហ៊ុន សែន ជាឪពុកប៉ុណ្ណោះ ដែលបង្ហាញឱ្យឃើញថាការដឹកនាំនៅកម្ពុជាសព្វថ្ងៃនេះ គឺជាប្រព័ន្ធកុម្មុយនីស្តសុទ្ធសាធ ព្រោះអំណាចដឹកនាំទាំងស្រុងគឺត្រូវស្ថិតនៅក្រោមបុគ្គលតែម្នាក់ ដែលផ្ទុយពីខ្លឹមសារដែលមានចែងក្នុងរដ្ឋធម្មនុញ្ញយ៉ាងជាក់ច្បាស់។

ទាក់ទិននឹងបញ្ហានេះ ប្រធានចលនាខ្មែរដើម្បីប្រជាធិបតេយ្យ អ្នកស្រី មូរ សុខហួរ ក៏បានអះអាងកាលពីពេលថ្មីៗនេះដែរថា ដើម្បីឱ្យការតស៊ូរបស់ពលរដ្ឋខ្មែរដែលចង់បានប្រជាធិបតេយ្យលេចចេញជារូបរាងពិតប្រាកដ ទាល់តែមានក្រុមប្រឹក្សាជាតិបង្រួបបង្រួមកម្ពុជាមួយដែលជាតំណាងឆន្ទៈពលរដ្ឋខ្មែរទាំងមូល៕




## Former Opposition Leader Urges for Resistance Movement to Change Hun Sen Clan Rule

Former opposition leader Sam Rainsy has called for the establishment of a resistance movement to change the government, the Hun Sen family clan that is leading Cambodia through a corrupt and treacherous dictatorship.

Former CNRP President Sam Rainsy wrote on his Facebook page on October 25 that the Cambodian people must change the corrupt and treacherous dictatorship that has been ruled by Hun Sen's family for more than 40 years.

He said the resistance movement must force the regime under Hun Sen to hold genuine and fair elections under the auspices of the international community through the United Nations.

He said that if there are free, fair and just elections, the dictatorship will no longer be able to seize power, which means that it will fall immediately.

Sam Rainsy said that all Cambodians who love freedom and justice must understand that the regime under Hun Sen will not arrange for Cambodia to have a free, fair and just election. This act is completely contrary to the provisions of the Constitution and the Paris Peace Agreement.

The former opposition leader claims that the Cambodian people should not wait for the election organized by the authorities today, because every election organized by the Hun Sen regime is a fraudulent election and violates the will of the Khmer people only.

Political analyst and chairman of the People's Forum, Kim Sok told The Cambodia Daily on October 25 that the communist leadership system in Cambodia is under the dictatorial authority of one individual, Hun Sen.

He said that Hun Sen is a person who has a selfish principle led only for the benefit of the power of the Hun family, regardless of the disaster to the nation.

Kim Sok stated that Hun Manet, the current Prime Minister, is only an aide to Hun Sen as his father, which shows that the leadership in Cambodia today is a purely communist system because the entire leadership is to be under one person, which is clearly contrary to the content of the Constitution.

In this regard, the President of the Khmer Movement for Democracy, Ms. Mu Sochua, also recently claimed that for the struggle of the Cambodian people who want democracy to become a reality, until there is a National Unity Council of Cambodia as a representative the will of all Cambodians.

# ព្រះរាជាខ្មែរប្រារព្ធទិវាគ្រងរាជ្យសម្បត្តិក្នុងរបបដែល អ្នកប្រាជ្ញហៅថារស់រានដោយប្លន់អំណាច

ដោយ ឌឹ ខេមបូឌា ដេលី

ប្រទេសកម្ពុជា ប្រារព្ធពិធីគ្រងរាជ្យសម្បត្តិខួប ២០ឆ្នាំនៃព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី យ៉ាងអធិកអធមជាងរាល់ឆ្នាំ ដែលមានរយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤ ខណៈក្រុមអ្នកឃ្លាំមើលសង្គមថាព្រះអង្គជាក្សត្រវងគ្រោះមួយព្រះអង្គដែលត្រូវប្រធានគណបក្សប្រជាជនកម្ពុជា លោក ហ៊ុន សែន ចាប់ទុកជាចំណាប់ខ្មាំងក្នុងការប្រើប្រាស់អំណាចតាមទំនើងចិត្តរបស់គាត់ ដើម្បីបំផ្លាញប្រជាធិបតេយ្យ។

នៅក្នុងព្រះរាជពិធីខួប ២០ឆ្នាំនៃការឡើងគ្រងរាជ្យសម្បត្តិនៃព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ថ្នាក់ដឹកនាំកំពូលៗនៅប្រទេសកម្ពុជាមានទាំងប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀត ព្រមទាំងរាជវង្សានុវង្សផងដែរក្នុងពិធីសាសនានៅឯព្រះបរមរាជវាំង។

គណៈកម្មការរៀបចំបុណ្យជាតិ-អន្តរជាតិ បានណែនាំឲ្យរាជធានី-ខេត្ត រៀបចំតាំងព្រះបរមឆាយាល័ក្ខណ៍ព្រះមហាក្សត្រ តុបតែងលម្អភ្លើងបំភ្លឺ ទង់ជាតិ ទង់សាសនា បដាពាក្យស្លោក ជាដើម ព្រមទាំងមានកម្មវិធីចុះសួរសុខទុក្ខអ្នកជំងឺតាមមន្ទីរពេទ្យ កុមារកំព្រា ជនពិការ និងចាស់ជរាដែលគ្មានទីពឹង។

នៅថ្ងៃទី២៩ ខែតុលា មានព្រះរាជពិធីថ្វាយព្រះពរនៅក្នុងព្រះបរមរាជវាំង ហើយនៅថ្ងៃទី៣០ ខែតុលា ជាថ្ងៃចុងក្រោយ នឹងមានរៀបចំមិទ្ទីញមហាជននៅខាងមុខព្រះបរមរាជវាំង។ បន្ទាប់មក នៅពេលយប់ គឺមានការអុជកាំជ្រួច រយៈពេល ៣យប់ជាប់គ្នា ដើម្បីញ៉ាំងឲ្យពិធីបុណ្យប្រព្រឹត្តទៅយ៉ាងមហោឡារិកជាងរាល់ឆ្នាំ។

ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា លោក ម៉ែន ណាត ប្រាប់សារព័ត៌មាន The Cambodia Daily កន្លងមកថា ក្នុងរយៈពេល ២០ឆ្នាំដែលព្រះមហាក្សត្រខ្មែរគ្រងរាជ្យសម្បត្តិ ព្រះអង្គបានបំពេញព្រះរាជមុខនាទី និងព្រះរាជកិច្ចតិចតួចបំផុត ហើយអាចបំពេញបានតែខាងផ្លូវមនុស្សធម៌ប៉ុណ្ណោះ ខណៈខាងកិច្ចការនយោបាយ ព្រះអង្គមិនបានបំពេញដូចមានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ។

លោក ម៉ែន ណាត អះអាងថា ការដែលព្រះអង្គមិនបានបំពេញព្រះរាជមុខនាទី និងព្រះរាជកិច្ចបែបនេះ គឺដោយសារព្រះអង្គជាក្សត្រវងគ្រោះមួយព្រះអង្គ



ដែលត្រូវលោក ហ៊ុន សែន ចាប់ទុកជាចំណាប់ខ្មាំងក្នុងការប្រើប្រាស់អំណាចទំនើងចិត្តរបស់គាត់ ដើម្បីបំផ្លាញប្រជាធិបតេយ្យ រំលោភច្បាប់ កម្ទេចក្រុមប្រឆាំង និងចាប់សកម្មជននានាជាដើម។

ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជារូបនេះបញ្ជាក់ថា ទង្វើអាក្រក់ដែលលោកហ៊ុនសែនបានធ្វើដោយយកព្រះមហាក្សត្រមកបាំងពីមុខសព្វថ្ងៃនេះ គឺជាចេតនាដ៏ស្មោកគ្រោកមួយដែលគាត់ចង់ឱ្យប្រជាពលរដ្ឋខ្មែរមួយនគរ បាត់ជំនឿលើព្រះមហាក្សត្ររបស់ខ្លួន ស្របពេលដែលលោក ហ៊ុន សែន ខ្លួនឯងកំពុងលើកតម្កើងខ្លួនស្មើនឹងស្តេចផែនដីក្នុងនាមជាប្រមុខរដ្ឋស្តីទីនៅពេលនេះទៅហើយនោះ។

ព្រះមហាក្សត្រព្រះបាទសម្តេចព្រះ

តទៅទំព័រទី១៥

# Khmer Kings Celebrate Day of Reign but Scholars Call Survival of Power

Cambodia Celebrates the 20th Anniversary of the Throne of His Majesty King Norodom Sihamoni every year from October 28 to 30, 2024 but social observers say he was one of the victims, he was taken hostage by CPP leader Hun Sen to use his arbitrary power to destroy democracy.

On the occasion of the 20th anniversary of the accession to the throne of His Majesty King Norodom Sihamoni, Cambodia's top leaders, including the president of the senate, the president of the national assembly, the prime minister and other high-ranking officials as well as the royal family attended in a religious ceremony at the Royal Palace.

The National-International Festival Organizing Committee has instructed the capitals and provinces to display the King's insignia, decorate the lights, flags, religious flags, banners, slogans, etc., and have a program to visit patients in hospitals, orphans, the disabled and the helpless elderly.

On October 29, there will be a royal blessing ceremony in the Royal Palace, and on October 30, the last day, there will be a public ceremony in front of the Royal Palace. Then, at night, there are fireworks for three nights in a row to make the festival more solemn than every year.

Mr. Men Nath, chairman of the Cambodian Watchdog Council, told The Cambodia Daily that in the 20 years since the reign of Khmer King, he had served in the royal court and the royal affairs are minimal and can only be fulfilled in the humanitarian way, while in the political affairs he did not fulfill as stated in the Constitution.

Mr. Men Nath claims that his failure to fulfill such royal duties was due to him being one of the victims of Hun Sen's capture to use his rebellious power to destroy democracy, break the law, destroy opposition groups and arrest activists.

The President of the Cambodian Watchdog Council stated that the evil act that Mr. Hun Sen did by hiding the King in front of him today is a dirty intention that he wants the Cambodian people to lose faith in the King. At the same time, Hun Sen himself is exalting himself as the king of the earth as the acting head of state currently.

King Norodom Sihamoni was elected to the throne on October 29, 2004, by nine councilors after his father, King Norodom Sihanouk, abdicated on October 7, 2004.

However, during his 20-year reign, it is alleged that he was subjected to all kinds of insults and abuse by ruling party leader Hun Sen, including more serious threats.

During 2005, Hun Sen threatened to dissolve the monarchy, meaning to eliminate the king from Cambodian territory if he did not sign the 2005 Supplementary Illegal Treaty so that he could use it to cut off Cambodian territory to Vietnam.

One should learn to look at the way of governance in Cambodia today as to whether it is the same or not, as the Greek scholars Plato and Aristotle said more than 2,000 years ago, to identify the leadership style of any leader.

Greek scholars say that a monarchy, even if ruled by a person like a monarchy, is not considered a dictator when it comes to protecting the interests of the people. If he begins to lead for selfish gain in violation of the law, then he becomes a tyranny dictator. The tyrant dictator shows signs to the people through some leadership style. These include the use of power, disobedience to laws, cruelty, oppression, pretending to be born angels or gods to lead people, not allowing anyone to criticize the deception of the eyes of the people by manipulating the election results to preserve the power oneself.

Greek scholar Aristotle said that the dictator came to power from below, robbing the legitimate ruler power and maintaining the power of the dynasty, using violence, threatening to deceive the public, hiring bodyguards to prevent the outbreak of war, for one dependent citizen to evict people from their group,

# មេដឹកនាំជំទាស់នៅក្រៅស្រុកប្រកាសបង្កើតរដ្ឋាភិបាលក្រៅស្រុកដើម្បីតតាំងនឹងរដ្ឋាភិបាលក្នុងស្រុក

ដោយ ខឺ ខេមបូឌា ដេលី

អតីតមេដឹកនាំបក្សប្រឆាំង លោក សម រង្ស៊ី ប្រកាសបង្កើតរដ្ឋាភិបាលតំណាងឱ្យឆន្ទៈពលរដ្ឋខ្មែរដោយពិតប្រាកដមួយ ចេញពីចលនាតស៊ូនៅក្រៅស្រុក ដើម្បីដណ្ដើមប្រទេសកម្ពុជាពីរបបដឹកនាំត្រកូលហ៊ុន យកមកប្រគល់ជូនប្រជារាស្ត្រខ្មែរវិញ។

លោក សម រង្ស៊ី សរសេរលើទំព័រហ្វេសប៊ុកខ្លួននៅថ្ងៃទី២៩ តុលា នេះថា ចលនាជាតិខ្មែរតស៊ូ នឹងឈានទៅបង្កើតរដ្ឋាភិបាលមួយពេញលក្ខណៈនៅក្រៅប្រទេសជាបណ្ដោះអាសន្ន ដើម្បីឈរជាតំណាងឱ្យឆន្ទៈពិតប្រាកដរបស់ប្រជារាស្ត្រខ្មែរស្រឡាញ់ជាតិ សេរីភាព និងយុត្តិធម៌ ដែលកំពុងរងការគាបសង្កត់ក្រោមការដឹកនាំក្នុងរបបត្រកូលហ៊ុនសព្វថ្ងៃនេះ។

លោក សម រង្ស៊ី លើកឡើងថា បេសកកម្មជាប្រវត្តិសាស្ត្រនៃចលនាជាតិខ្មែរតស៊ូ គឺត្រូវតែដណ្ដើមប្រទេសកម្ពុជាពីរបបដឹកនាំត្រកូលហ៊ុន យកមកប្រគល់សងជូនប្រជារាស្ត្រខ្មែរវិញ ដែលជាម្ចាស់ទឹកម្ចាស់ដីតែមួយគត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋខ្មែរពីគ្រប់ទិសទីដែលជាអ្នកស្នេហាជាតិ ស្នេហាប្រជាធិបតេយ្យ ស្រឡាញ់សេរីភាព និងការពារយុត្តិធម៌សង្គម។

មេដឹកនាំបក្សប្រឆាំងរូបនេះបញ្ជាក់ថា តាមរយៈនៃការបោះឆ្នោតក្លែងក្លាយជាបន្តបន្ទាប់មកនេះ លោក ហ៊ុន សែន បានប្លន់អំណាចពីប្រជារាស្ត្រខ្មែរគ្រប់អាណត្តិ និងយកប្រទេសកម្ពុជាធ្វើជាកម្មសិទ្ធិឯកជនសម្រាប់ក្រុមគ្រួសារគាត់ថែមទៀត។

លោក សម រង្ស៊ី បន្តថា ត្រកូលហ៊ុន និងរបបខុសច្បាប់មួយនេះ គ្មានសិទ្ធិមកធ្វើជាតំណាងឱ្យឆន្ទៈប្រជារាស្ត្រខ្មែរឡើយ។

មេដឹកនាំបក្សកាន់អំណាច លោក ហ៊ុន សែន ធ្លាប់អះអាងកាលពីពេលកន្លងទៅថា អ្នកដែលចង់ដឹករំលើងឫសគល់ត្រកូលហ៊ុន ទាល់តែពួកគេយកឈ្នះគណបក្សប្រជាជនកម្ពុជាជាមុនសិន ព្រោះថាសូម្បីមន្ត្រីជាន់ខ្ពស់បក្សកាន់អំណាច ក៏គ្មាននរណាម្នាក់ហ៊ានដឹករំលើងឫសគល់ត្រកូលហ៊ុនដែរ។

លោក ហ៊ុន សែន អះអាងថា រដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ហ៊ានធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីកម្ទាត់ឱ្យអស់នូវអង្គការចាត់តាំងជ្រុលនិយមនៅក្រៅស្រុក ទោះក្នុងតម្លៃណាក៏ដោយ ដើម្បីទប់ស្កាត់នូវចេតនាដែលអាចនាំគ្រោះថ្នាក់ដល់ប្រទេសជាតិ។

ទាក់ទិននឹងបញ្ហានេះ ប្រធានវិទ្យុផ្សាយសំឡេងប្រជាធិបតេយ្យ វីអូឌី លោក ប៉ា ងួនទៀង បានលើកឡើងកាលពីពេលថ្មីៗនេះថា លោក ហ៊ុន សែន ជាមនុស្សដែលមានប្រវត្តិប្លន់អំណាចពីអ្នកដទៃដើម្បីផលប្រយោជន៍ខ្លួនឯង និងក្រុមគ្រួសាររបស់គាត់រហូតមក។

លោក ប៉ា ងួនទៀង រំលឹកថា ដើម្បីគ្រប់គ្រងអំណាចផ្ដាច់មុខ លោក ហ៊ុន សែន ហ៊ានបង្ក្រាបចលនាប្រឆាំងនឹងអំណាចគ្រួសាររបស់គាត់គ្រប់បែបយ៉ាង មិនថាក្រុមប្រឆាំង ឬមន្ត្រីគណបក្សប្រជាជនកម្ពុជាក្នុងសម្បុកតែមួយនោះឡើយ។

លោកបញ្ជាក់ថា កន្លងមក មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា ដូចជាលោក ប៉ែន សុវណ្ណ លោក ចាន់ ស៊ី និងលោក ជា ស៊ីម ជាដើម សុទ្ធសឹងតែត្រូវលោក ហ៊ុន សែន ប្លន់អំណាចដើម្បីឱ្យគ្រួសាររបស់គាត់អាចគ្រប់គ្រងប្រទេសកម្ពុជាដោយផ្ដាច់មុខរហូតដល់ពេលនេះ។

តមកពីទំព័រទី ១៤

## ព្រះរាជាខ្មែរប្រារព្ធពិធីគ្រងរាជសម្បត្តិ

បរមនាថ នរោត្តម សីហមុនី ត្រូវបានសម្រេចជ្រើសតាំងឡើងគ្រងរាជ្យសម្បត្តិនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ ដោយក្រុមប្រឹក្សារាជ្យសម្បត្តិចំនួន ៩រូប ក្រោយព្រះបិតាព្រះអង្គ គឺព្រះបាទសម្ដេចព្រះនរោត្តម សីហនុ បានដាក់រាជ្យសម្បត្តិនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៤។

ទោះជាយ៉ាងណាក៏ដោយរយៈពេលនៃការគ្រងរាជ្យរបស់ព្រះអង្គអស់ ២០ឆ្នាំមកនេះ ត្រូវគេលើកឡើងថា ព្រះអង្គបានរងនូវការប្រមាថ និងរំលោភបំពានពីមេដឹកនាំបក្សកាន់អំណាច លោក ហ៊ុន សែន គ្រប់បែបយ៉ាង រួមទាំងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរថែមទៀត។

កាលពីអំឡុងឆ្នាំ២០០៥ លោក ហ៊ុន សែន បានគំរាមរំលាយរបបរាជានិយម គឺមានន័យថា បំបាត់ស្ដេចចេញពីទឹកដីខ្មែរតែម្ដង ប្រសិនបើព្រះអង្គមិនឡាយព្រះហស្តលើសន្ធិសញ្ញាខុសច្បាប់ បំពេញបន្ថែមឆ្នាំ២០០៥ ដើម្បីឱ្យគាត់អាចប្រើប្រាស់សន្ធិសញ្ញានេះកាត់ទឹកដីខ្មែរឱ្យទៅវៀតណាម ទេនោះ។



គួររៀនពិនិត្យមើលរបៀបគ្រប់គ្រងនៅស្រុកខ្មែរសព្វថ្ងៃជាការរៀនសូត្រ ថាតើវាដូច ឬត្រូវនឹងអ្វីអ្នកប្រាជ្ញក្រិក ប្លាតុង និង អារីស្តូត និយាយកាលពីជាង ២០០០ឆ្នាំមុនឬទេ ដើម្បីសម្គាល់របៀបដឹកនាំនៃមេដឹកនាំណាម្នាក់។

អ្នកប្រាជ្ញក្រិក និយាយថា៖ របបដឹកនាំ ទោះជាដឹកនាំដោយមនុស្សម្នាក់ ដូចជាស្ដេច monarchy ក៏ដោយ បើគិតអំពីកិច្ចការពារផលប្រយោជន៍ប្រជារាស្ត្រជាធំ គេមិនទាន់ចាត់ទុកជាមេដឹកនាំផ្ដាច់ការទេ។ បើចាប់ផ្ដើមដឹកនាំដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនបែបអត្តទត្ត ប្រយោជន៍ បំពានច្បាប់ហើយ នោះគេក្លាយជាមេដឹកនាំផ្ដាច់ការ tyranny ហើយ។ អ្នកដឹកនាំផ្ដាច់ការ tyrant បង្ហាញសញ្ញាឲ្យពលរដ្ឋដឹងតាមរយៈរបៀបដឹកនាំមួយចំនួន មានដូចជា ការប្រើអំណាច មិនគោរពច្បាប់ទម្លាប់ កាចសហាវ ជិះជាន់សង្កត់សង្កិន តាំងខ្លួនថាទេវតាចាប់កំណើត ឬអាទិទេពជប់ឲ្យមកដឹកនាំមនុស្សការមិនអនុញ្ញាតឲ្យនរណាម្នាក់រិះគន់ ការបំភាន់ភ្នែកមនុស្សម្នាតាមរយៈការរៀបឆាកបោះឆ្នោតលួចបន្លំលទ្ធផលដើម្បីរក្សាអំណាចខ្លួន។

អ្នកប្រាជ្ញក្រិក អារីស្តូត និយាយទៀតថា៖ ជនផ្ដាច់ការឡើងកាន់អំណាចពីផ្ទាក់ក្រោម ដោយប្លន់យកអំណាចពីមេដឹកនាំស្របច្បាប់ ហើយរក្សាអំណាចតវង្សត្រកូល ដោយប្រើអំពើហិង្សាគំរាមបន្លំភ្នែកសាធារណជន ជួលអង្គរក្សការពារ បំភ័យអំពីការផ្ទុះសង្គ្រាម ឲ្យពលរដ្ឋពឹងតែលើខ្លួនម្នាក់ បណ្ដេញមនុស្សពីក្រុមខ្លួន ធ្វើឃាតរឺបអូសយកទ្រព្យសម្បត្តិគេ។

# អតីតមេបក្សជំទាស់ជំរុញឱ្យមានចលនាតស៊ូប្រឆាំង ដើម្បីផ្លាស់ប្តូរការគ្រប់គ្រងនៃរបបត្រកូលហ៊ុន

អតីតមេដឹកនាំបក្សប្រឆាំង លោក សម រង្ស៊ី ជំរុញឱ្យមានការរៀបចំចលនាតស៊ូមួយដើម្បីផ្លាស់ប្តូររដ្ឋាភិបាលក្រុមគ្រួសារត្រកូល ហ៊ុន ដែលកំពុងដឹកនាំប្រទេសកម្ពុជាតាមរបបផ្តាច់ការពុករលួយ និងក្បត់ជាតិខ្មែរ។

អតីតប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី សរសេរលើទំព័រហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី២៥ តុលា នេះ ថា ប្រជាពលរដ្ឋខ្មែរត្រូវតែផ្លាស់ប្តូររបបផ្តាច់ការ ពុករលួយ និងក្បត់ជាតិ ដែលកំពុងដឹកនាំដោយក្រុមគ្រួសារត្រកូលហ៊ុនរបស់លោក ហ៊ុនសែន ជាង ៤០ឆ្នាំមកនេះ។

លោកថា ចលនាតស៊ូនេះត្រូវតែបង្ខំឲ្យរបបដឹកនាំដែលកំពុងគ្រប់គ្រងដោយលោក ហ៊ុន សែន រៀបចំឱ្យមានការបោះឆ្នោតពិតប្រាកដ ត្រឹមត្រូវ ដោយមានការឃ្លាំមើលពីសហាគមន៍អន្តរជាតិតាមរយៈអង្គការសហប្រជាជាតិ ជាដើម។

លោកបន្តថា ឱ្យតែមានការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ របបផ្តាច់ការនឹងមិនអាចក្តោបក្តាប់អំណាចតទៅទៀតបានឡើយ គឺមានន័យថានឹងត្រូវធ្លាក់ពីតំណែងមួយរំពេច។

លោក សម រង្ស៊ី លើកឡើងថា ពលរដ្ឋខ្មែរគ្រប់គ្នាដែលស្រឡាញ់សេរីភាព និងយុត្តិធម៌ ត្រូវយល់ថារបបដែលកំពុងគ្រប់គ្រងដោយលោក ហ៊ុន សែន នឹងមិនរៀបចំឱ្យប្រទេសកម្ពុជាមានការបោះឆ្នោតមួយដែលប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌បានទេ ដែលទង្វើបែបនេះគឺផ្ទុយពីខ្លឹមសារដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសទាំងស្រុង។

អតីតមេដឹកនាំប្រឆាំងរូបនេះអះអាងថា ពលរដ្ឋខ្មែរមិនត្រូវរង់ចាំការបោះឆ្នោតដែលរៀបចំដោយរដ្ឋអំណាចសព្វថ្ងៃនេះទេ ព្រោះថារាល់ការបោះឆ្នោតម្តងៗដែលរៀបចំដោយរបបលោក ហ៊ុន សែន សុទ្ធតែជាការបោះឆ្នោតក្លែងបន្លំបំភ្លៃ និងរំលោភឆន្ទៈប្រជារាស្ត្រខ្មែរតែប៉ុណ្ណោះ។

អ្នកវិភាគនយោបាយ និងជាប្រធានវេទិកាពលរដ្ឋ លោក គឹម សុខ ប្រាប់សារព័ត៌មាន The Cambodia Daily នៅថ្ងៃទី២៥ តុលា នេះថា ប្រព័ន្ធដឹកនាំកុម្មុយនីស្តត្រកូលហ៊ុននៅប្រទេសកម្ពុជា គឺស្ថិតនៅក្រោមអំណាចផ្តាច់ការអាជ្ញាទំនើងចិត្តរបស់បុគ្គលតែម្នាក់គត់ គឺលោក ហ៊ុន សែន។



ប្រជាពលរដ្ឋក្រៅស្រុកចេញធ្វើបាតុកម្មដើម្បីផ្លាស់ប្តូរការគ្រប់គ្រងរបបត្រកូល ហ៊ុន

លោកថា លោក ហ៊ុន សែន គឺជាមនុស្សដែលមានគោលការណ៍អាត្មានិយម ដឹកនាំដើម្បីតែផលប្រយោជន៍អំណាចគ្រួសារហ៊ុនតែមួយមុខប៉ុណ្ណោះ ដោយមិនខ្វល់ពីគ្រោះមហន្តរាយចំពោះប្រទេសជាតិឡើយ។

លោក គឹម សុខ បញ្ជាក់ថា លោក ហ៊ុន ម៉ាណែត ដែលជានាយករដ្ឋមន្ត្រីសព្វថ្ងៃនេះ គ្រាន់តែជាជំនួយការឲ្យលោក ហ៊ុន សែន ជាឪពុកប៉ុណ្ណោះ ដែលបង្ហាញឱ្យឃើញថា ការដឹកនាំនៅកម្ពុជាសព្វថ្ងៃនេះ គឺជាប្រព័ន្ធកុម្មុយនីស្តសុទ្ធសាធ ព្រោះអំណាចដឹកនាំទាំងស្រុងគឺត្រូវស្ថិតនៅក្រោមបុគ្គលតែម្នាក់ ដែលផ្ទុយពីខ្លឹមសារដែលមានចែងក្នុងរដ្ឋធម្មនុញ្ញយ៉ាងជាក់ច្បាស់។

ទាក់ទិននឹងបញ្ហានេះ ប្រធានចលនាខ្មែរដើម្បីប្រជាធិបតេយ្យ អ្នកស្រី មូរ សុខហួរ ក៏បានអះអាងកាលពីពេលថ្មីៗនេះដែរថា ដើម្បីឱ្យការតស៊ូរបស់ពលរដ្ឋខ្មែរដែលចង់បានប្រជាធិបតេយ្យលេចចេញជារូបរាងពិតប្រាកដ ទាល់តែមានក្រុមប្រឹក្សាជាតិបង្រួបបង្រួមកម្ពុជាមួយដែលជាតំណាងឆន្ទៈពលរដ្ឋខ្មែរទាំងមូល៕



លោក សម រង្ស៊ី ដឹកនាំបាតុកម្មដើម្បីផ្លាស់ប្តូរការគ្រប់គ្រងរបបត្រកូល ហ៊ុន

# Opposition Leaders Announce Formation of Oversea Government to Counter Local Government

Former opposition leader Sam Rainsy announces the formation of a government that truly represents the will of the Cambodian people from the overseas resistance movement to retake Cambodia from the Hun Sen regime and return it to the Cambodian people.

Sam Rainsy wrote on his Facebook page on October 29 that the Khmer National Movement will lead to the formation of a full-fledged government abroad temporarily to stand as a representative of the true will of the Cambodian people, patriotism, freedom and justice, which is being suppressed under the leadership of the current Hun Sen clan regime.

Sam Rainsy said that the historical mission of the Khmer National Struggle Movement is to take Cambodia from the Hun Sen clan rule and return it to the Khmer people, who are the sole owners of the land with the participation of Cambodians from all over who are patriotic, love democracy, love freedom and protect social justice.

The opposition leader stated that through a series of fraudulent elections Hun Sen robbed the power of the Cambodian people in all terms and made Cambodia more private to his family.

Sam Rainsy said that this illegal Hun Sen clan and regime has no right to represent the will of the Cambodian people.

Ruling party leader Hun Sen has claimed in the past that those who want to uproot the Hun Sen clan until they defeat the CPP first, because not even senior ruling party officials dare to dig the roots of the clan.

Hun Sen claims that the CPP-led government dares to do everything possible to eliminate extremist organizations abroad at any cost to prevent currents that could endanger the nation.

Regarding this issue, the President of the Voice of Democracy VOD, Mr. Pa Nguon Teang, recently mentioned that Hun Sen is a person who has a history of stealing power from others for the benefit of himself and his family.

Pa Nguon Teang reminded that to control the monopoly power, Hun Sen dared to suppress any movement against the power of his family, whether it was the opposition group or the CPP officials in the same nest.

He said that in the past, senior officials of the Cambodian People's Party, such as Mr. Pen Sovann, Mr. Chan Si and Mr. Chea Sim, were all robbed by Hun Sen so that his family could rule Cambodia monopoly until now.

តមកពីទំព័រទី ០៣

# កម្ពុជាអាចនឹងបាត់បង់ដី៥១គីឡូម៉ែត្រ

សភាកម្ពុជា និងជាអ្នកស្រាវជ្រាវបញ្ហាព្រំដែន របស់រដ្ឋាភិបាលបានបដិសេធការអះអាងនេះតំបន់ដាក់ដាំដាក់ហ្វិតទឹកដីខេត្តមណ្ឌលគិរីនេះ លោក សុខ ទូច បាននិយាយថា មិនបានបាត់បង់ទៅប្រទេសវៀតណាមដូចការលើកឡើងនោះទេ ប៉ុន្តែគ្រាន់ថាអោយគាត់ទៅមើលសិនទៅៗ អត់ទាន់មានបញ្ហាអីទេនៅដដែលទេពេលខ្ញុំដើរកាត់ហ្នឹងមានទាំងទាយខាំខ្ញុំសឹងពេញខ្លួនទាំងអស់ហើយអត់មានទេអត់ទាន់មានអនុម័តអីទេហើយមិនមែន ៥០គីឡូទេ គឺ២៧គីឡូអោយគាត់ទៅមើលសិនទៅខ្ញុំពិបាកនិយាយណាស់ព្រោះអាឡូវវាចូលជម្ងឺមួយអានិយាយតៗគ្នា ហើយអត់បានមើល នេះបើតាមការសម្ភាសន៍នៅវិទ្យុសម្លេងប្រជាធិបតេយ្យVODប៉ុន្តែនៅពេលសួរថា តើវៀតណាមពិតជាបានកសាងហេដ្ឋារចនាសម្ព័ន្ធ និងសំណង់រឹងមាំ ឬគ្រប់គ្រងទាំងស្រុងក្នុងតំបន់ លោកមិនបានឆ្លើយសំណួរនោះទេដោយសំអាងថានឹងផ្ញើវីដេអូអោយ ដោយឡែកលោក ម៉ែន ណាត ប្រធានក្រុមឃ្លាំមើលកម្ពុជា បានលើកឡើងថាការដែលវៀតណាមកសាងសំណង់រឹងមាំ ឬហេដ្ឋារចនាសម្ព័ន្ធលើដីខ្មែរគឺមានន័យថាវៀតណាមបានរំលោភយកដីខ្មែរមួយវិញទៀតលោកថាបើរដ្ឋាភិបាលខ្មែរថា ដីខ្មែរមិនត្រូវបានវៀតណាមរំលោភយក ហេតុអ្វីមិនដេញវៀតណាមចេញពីតំបន់នោះ ដូចធ្លាប់ធ្វើជាមួយភាគីឡាវកន្លងទៅ ហេតុអ្វីបណ្តែតបណ្តោយឲ្យវៀតណាមបន្តឈរជើងនៅលើទឹកដីខ្មែរថែមទាំងកសាងសំណង់រឹងបែបនេះ សម្រាប់លោក ម៉ែន ណាត ការអះអាងរបស់លោក សុខ ទូច គ្រាន់តែជាការជួយបិទបាំងកំហុសរបស់ លោក ហ៊ុន សែន មកដែលបម្រើមហិច្ឆតាវៀតណាមលើទឹកដីខ្មែរតែប៉ុណ្ណោះ តាមច្បាប់គឺគ្មានកាអនុញ្ញាតិណាមួយអំពីការសំណង់ប្លង់រឹងអីទេ ហាមសំណង់អីទាំងអស់នៅតំបន់ដែលប្រទាញប្រទង់ហើយបើសិនជាមានឬក៏បានធ្វើហើយ បើបានធ្វើហើយនៅលើតំបន់ប្រទាញប្រទង់ហ្នឹងរដ្ឋាភិបាលកម្ពុជាត្រូវតែតវ៉ាទៅវៀតណាម តាមរយៈលិខិតកំណត់ទូត ឬក៏តវ៉ាអីតាមផ្លូវទូតហ្នឹង លិខិតត្រូវធ្វើជាដាច់ខាតតែម្តងនេះយើងលើកឡើងថា ក្នុងករណីដែលរដ្ឋាភិបាលកម្ពុជាមានស្មារតីជាតិខ្លះយកចិត្តទុកដាក់ពីរឿងទឹកដីជាតិខ្លះម្លោះហើយពួកគេត្រូវតវ៉ា ឬធ្វើការតវ៉ាតាមរយៈកំណត់ទូតដើម្បីបញ្ឈប់សកម្មភាពទាំងឡាយណា ដែលសាងសង់នៅលើតំបន់ប្រទាញប្រទង់ហ្នឹង អាហ្នឹងបានធ្វើតាមផ្លូវច្បាប់ប៉ុន្តែបើតាមស្ថានភាពបច្ចុប្បន្ននេះកម្ពុជាព្រមព្រៀងចុះហត្ថលេខាសន្ធិសញ្ញាព្រំដែនកាលតាំងពី ឆ្នាំ២០០៥ និងឆ្នាំ២០១៩ ហ្នឹងហើយបានកែសម្រួល



សមុទ្រឈើនៅខេត្តកណ្ឌលគិរី

ខ្សែបន្ទាត់ព្រំដែនថ្មីរួចហើយ អីចឹងអាខ្សែបន្ទាត់ព្រំដែនថ្មីហ្នឹងច្បាស់ណាស់ហើយថារអិលធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់វៀតណាមហើយវៀតណាមគេកំណត់ព្រំដែនហ្នឹងគឺកំណត់ទៅតាមខ្សែបន្ទាត់ព្រំដែនថ្មីហ្នឹងម្លោះហើយកម្ពុជាពិបាកក្នុងការតវ៉ាជាមួយគ ព្រោះជារដ្ឋាភិបាលដែលមិនតំណាងអោយស្មារតីជាតិពិតប្រាកដ លោក ម៉ែន ណាត ទទូចឱ្យមេដឹកនាំខ្មែរត្រូវគិតគូរពីបញ្ហាបូរណភាពទឹកដី សើរើសន្ធិសញ្ញាព្រំដែនខុសច្បាប់ និងប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ អាយ.ស៊ី.ជេ (I.C.J) ទាមទារទឹកដីរបស់ដូនតាខ្មែរមកវិញម្យ៉ាងវិញទៀត បើយោងតាមរបាយការណ៍របស់ក្រុមការងារមួយរយរាត្រីដែលចេញផ្សាយកាលពីខែសីហា ឆ្នាំ២០១៩ បានឲ្យដឹង

តទៅទំព័រទី២២

# Cambodia May Lose 51 Square Kilometers of Land Bordering Mondulkiri Province

From Page 03

according to an interview with Voice of Democracy VOD, but when asked if Vietnam has really built strong infrastructure and construction or completely controlled the region? He did not answer the question, citing a separate video. Men Nath, head of the Cambodian watchdog, said that the fact that Vietnam was building strong structures or infrastructure on Cambodian soil meant that Vietnam had encroached on Cambodian land. On the other hand, he said that if the Cambodian government says that Khmer land has not been encroached upon by Vietnam, why not expel Vietnam from the area as it did with the Lao side in the past? Why let Vietnam continue to stand on Cambodian territory and build construction like this? For Mr. Men Nath, Mr. Sok Touch's claim is only to help cover up the mistake of Hun Sen to serve Vietnam's ambitions on Cambodian territory, according to the law, there is no permission for the construction of a solid constructions. It must prohibit all construction in the conflict zone, if there is or has been done, and if it has been done in the conflict zone, the Cambodian government must protest to Vietnam through the diplomatic note or protest through the diplomatic corridor. We say that in case the Cambodian government has some national spirit, cares about some national territory, and they have to protest or protest through diplomatic notes to stop any activities built on the conflict zone. That is done legally. But according to the current situation, Cambodia agreed to sign the border treaty in 2005 and 2019 and revised the new border line, so it is clear that the new border line falls under Vietnamese control and that Vietnam is demarcating the border, following the new border line. Therefore, it is difficult for Cambodia to protest with them because it is a government that does not represent the true national spirit.

Men Nath urges Cambodian leaders to consider territorial integrity issues over illegal boundary treaty and to appeal to the International Court of Justice to recover the lands of the Khmer ancestors. On the other hand, according to the report of the group One Hundred Nights released in August 2019, said that Vietnam has built a tar road at the Dak Dam canal and from Bo Prang checkpoint to install in O Borng and build a military post along the Dak Dam border in Dak Dam commune, Rovang district, Mondulki province, adjacent to Kwang Teuk commune, Dak Lang district, Dak Nang province, Vietnam. From the border gate Dak Dam about 800 meters from the Vietnamese checkpoint built in the area of disagreement between Cambodia and Vietnam over 51 square kilometers of land that Cambodia and Vietnam have not yet agreed on.

On the other hand, the Cambodian government demarcated the border to take the area, which Vietnam called Hoch, until O Tang Mae and O Ploy down to Sre Pok River, the old border from the French colonial period.

Oum Sam An said that when Vietnam took control of the Dak Dam area in Mondulkiri, it started with Hun Sen reviving the illegal border treaty controlled by Vietnam in 2005 under the message of threatening to dissolve the monarchy to achieve Vietnam's ambition to swallow Khmer territory. Article 440 of the Penal Code stipulates that troops from the handover of a foreign state or guiding agency, in whole or in part on national roads, must be punished for treason, a life imprisonment.

# ចលនាមាតាធម្មជាតិអំពាវនាវឱ្យសាធារណជនបរិច្ចាគសប្បុរសទានដល់ការតស៊ូពីពន្ធនាគារ

#ចលនាមាតាធម្មជាតិកម្ពុជា (#MotherNature #Cambodia) អំពាវនាវឱ្យប្រជាពលរដ្ឋខ្មែរចូលរួមបរិច្ចាគថវិកាជួយដល់យុវជនចលនាមាតាធម្មជាតិចំនួន ៥នាក់ដែលកំពុងតស៊ូនឹងភាពអយុត្តិធម៌ក្នុងពន្ធនាគារ។

ចលនាមាតាធម្មជាតិកម្ពុជា បានសរសេរលើទំព័រហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី២៥ តុលា នេះថា សូមប្រជាពលរដ្ឋបច្ចុប្បន្ននេះ។

កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ សាលាដំបូងរាជធានីភ្នំពេញ បានប្រកាសសាលក្រមផ្តន្ទាទោសសកម្មជនចលនាមាតាធម្មជាតិ ១០នាក់ និងបានចាប់ឃុំខ្លួនចំនួន ៥នាក់ ក្រោមបទចោទប្រកាន់ #រួមគំនិតក្បត់និង#ប្រមាថព្រះមហាក្សត្រ ដែលត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចន្លោះពី ៦ ទៅ ៨ឆ្នាំ ព្រមទាំងតម្រូវឱ្យដើមខែតុលា ឆ្នាំ២០២៤ នេះ ដោយទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជាដោះលែងសកម្មជនទាំង ៥នាក់ដោយឥតលក្ខខណ្ឌ។

ចំណែកឯប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា លោក ម៉ែន ណាត ប្រាប់សារព័ត៌មាន The Cambodia Daily នៅថ្ងៃទី២៥ តុលា នេះថា ការចាប់ខ្លួនសកម្មជនបរិស្ថានដាក់ពន្ធនាគារជាផ្នែកមួយដែលនាំឱ្យប៉ះពាល់សិទ្ធិមនុស្សរូបនេះបញ្ជាក់ថា ការចាប់សកម្មជនបរិស្ថានដាក់គុក គឺមានន័យស្មើនឹងបើកដៃឱ្យឧក្រិដ្ឋជនព្រៃឈើបំផ្លាញបរិស្ថានបន្តទៀត ដូច្នេះហើយបានជាព្រៃឈើខ្មែរតែងរងនូវការបំផ្លាញពីមួយឆ្នាំទៅមួយឆ្នាំដោយសារតែមានការគប់គិតគ្នារវាងមន្ត្រីរដ្ឋាភិបាល និងក្រុមឧក្រិដ្ឋជនទាំងនោះ។

កាលពីអំឡុងឆ្នាំ២០២១ សកម្មជនចលនាមាតាធម្មជាតិ ធ្លាប់ទទួលបានពានរង្វាន់អ្នកការពារសិទ្ធិមនុស្សជួរមុខប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (Frontline Defender for Asia Pacific) ពីអង្គការ



ចលនាមាតាធម្មជាតិអំពាវនាវអោយសាធារណជនបរិច្ចាគសប្បុរសទានដល់ការតស៊ូពីពន្ធនាគារ

ខ្មែរដែលស្រឡាញ់#បរិស្ថាន ចូលរួមគាំទ្រសកម្មជនបរិស្ថាននៅប្រទេសកម្ពុជា ដើម្បីអនាគតភពផែនដីសម្រាប់កូនចៅជំនាន់ក្រោយ ព្រោះថវិកាបរិច្ចាគពីអ្នកចូលរួមទាំងអស់ ពិតជាមានតម្លៃអស្ចារ្យណាស់ក្នុងកិច្ចការងារដើម្បីបរិស្ថាន។

ប្រភពដដែលអំពាវនាវឱ្យប្រជាពលរដ្ឋខ្មែរចូលរួមគាំទ្រសកម្មជនបរិស្ថានកម្ពុជាទាំង ៥នាក់ ដែលកំពុងតស៊ូក្នុង#ពន្ធនាគារតទល់នឹងប្រព័ន្ធយុត្តិធម៌នៃរបបក្រុងភ្នំពេញដែលបានចោទប្រកាន់ និងចាប់ឃុំខ្លួនពួកគេទាំងអយុត្តិធម៌ក្នុងពេលឃុំខ្លួនក្នុងពន្ធនាគារនៅតាមខេត្តចំនួនប្រាំខុសៗគ្នាផងដែរ។

ជុំវិញការចាប់ខ្លួននេះ អង្គការក្រៅរដ្ឋាភិបាលដែលមានមូលដ្ឋាននៅក្រៅស្រុកចំនួន ៦៧ស្ថាប័ន ដូចជា អង្គការបណ្តាញសេរីភាពបញ្ចេញមតិអាស៊ីអាគ្នេយ៍ (Southeast Asia Freedom of Expression Network) អង្គការបណ្តាញយុវជនអាកាសធាតុរស់ឡើងវិញ (Youth Climate Resilience Network) និងអង្គការយុវជនដើម្បីសហគមន៍បៃតង (Youth for Green Communities) ជាដើម បានចេញសេចក្តីថ្លែងការណ៍រួមគ្នាកាលពីយ៉ាងធ្ងន់ធ្ងរ ហើយក៏ជាកត្តាមួយនាំឱ្យប៉ះពាល់ដល់ការវិនិយោគ និងវិស័យទេសចរណ៍នៅកម្ពុជាដែរ។

លោក ម៉ែន ណាត លើកឡើងថា សកម្មជនបរិស្ថានមិនមែនជាឧក្រិដ្ឋជនព្រៃឈើទេ ប៉ុន្តែត្រូវរដ្ឋាភិបាលចាប់ដាក់គុកទាំងអយុត្តិធម៌។ ផ្ទុយទៅវិញ ឧក្រិដ្ឋជនព្រៃឈើ ដូចជា ឧកញ៉ា ទ្រី ភាព ឧកញ៉ា លី យ៉ុងផាត់ ជាដើម មិនត្រឹមតែគ្មានទោសទេ ថែមទាំងត្រូវរដ្ឋាភិបាលផ្តល់សិទ្ធិឱ្យពួកគេប្រព្រឹត្តបទឧក្រិដ្ឋកាន់តែខ្លាំងថែមទៀត។

ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា

Frontline Defender ជុំវិញកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការការពារសិទ្ធិពលរដ្ឋ និងការការពារធនធានធម្មជាតិនៅកម្ពុជា។

ក្រៅពីនោះ សកម្មជនបរិស្ថានទាំងនេះក៏បានទទួលពានរង្វាន់ Rights Livelihood Award ជុំវិញសកម្មភាពការពារធនធានធម្មជាតិនៅប្រទេសកម្ពុជាពីរដ្ឋាភិបាលប្រទេសស៊ុយអែតកាលពីចុងខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅដែរ៕

តមកពីទំព័រទី ០៩

## បោះឆ្នោតប្រធានាធិបតីអាមេរិកាំង...

ឃោសនានៅ ហ្វីឡាដែលហៀ គាំទ្រជាមួយ ឧណាល ត្រាំ នៅ៤សប្តាហ៍ មុនពេលបោះឆ្នោតផ្តាច់ព្រ័ត្រថ្ងៃទី៥វិច្ឆិកា២០២៤ ខាងមុខ។ ការ«បោះឆ្នោតផ្ញើរសម្លេង»បានចាប់ផ្តើមពីថ្ងៃ ទី១តុលា២០២៤ នេះទៅហើយ គេសង្កេតឃើញថា«កាមាឡា ហារីស»កំពុងឃោសនាពង្រីកចំនួនអ្នកដែលមិនទាន់បានសម្រេចចិត្ត ចំណែកឯខាង ឧណាល ត្រាំ វិញ កំពុងតែពង្រឹងមូលដ្ឋានខ្លួន ខាងគណបក្សសាធារណរដ្ឋនៅឡើយ។

ការស្ទង់មតិចុងក្រោយនេះ បានឲ្យកាមាឡា ហារីស បាន ៤៨% ទល់នឹង ឧណាល ត្រាំ ៤៦% ដែលជាការស្ទង់មតិលើឆ្នោត«ប្រជាប្រិយភាព » ។ លោកស្រី ហ៊ីឡារី គ្លីងតុន បានឈ្នះឆ្នោតលើលោក ឧណាល ត្រាំចំនួនប្រមាណ៣លានសន្លឹក តែបែរជាចាញ់ដំណែងប្រធានាធិបតីទៅ ឧណាល ត្រាំ ទៅវិញ ដោយសារតែការបោះឆ្នោតប្រធានាធិបតីអាមេរិកាំងគឺជាការបោះឆ្នោត«មិនចំពោះ» បេក្ខជនណា«ឈ្នះសន្លឹកឆ្នោតប្រជាប្រិយនៅក្នុងរដ្ឋមួយ បេក្ខជននោះយកដំណាងរដ្ឋទាំងអស់មកខាងខ្លួន»។ ដូច្នេះ បេក្ខជនឬបេក្ខនារី ជាគូរប្រកួតត្រូវយកឲ្យបាននូវ«ដំណាងរដ្ឋសរុបចំនួន២៧០យ៉ាងតិចបំផុត»ដើម្បីឲ្យអាចឈ្នះឆ្នោត ជាប្រធានាធិបតីសហរដ្ឋអាមេរិកបាន ដែលជាជោគជ័យរបស់ លោក ត្រាំ នាពេលនោះ៕

តមកពីទំព័រទី ១០ **តារា ហុង ឈ្នះឆ្នោតជុំទី1...**

អាមេរិកនេះនៅឆ្នាំ២០១៣ មានអាយុ១៣ឆ្នាំមិនបាន ចងចាំពីនយោបាយនៅកម្ពុជាទេ, ខ្ញុំរៀននៅសាលា«មីឌលសិក» រៀនពីនយោបាយ ពីវប្បធម៌អាមេរិកាំង ពីតម្លៃនៃប្រជាជនអាមេរិក ពីសេរីភាព ពីប្រជាធិបតេយ្យ... ខ្ញុំក៏មិនដឹងច្បាស់ពីនយោបាយនៅកម្ពុជានោះដែរ... តែខ្ញុំបានឮពីពលរដ្ឋខ្មែរជាច្រើនថា គេចង់ឃើញការផ្លាស់ប្តូរចេញពីនយោបាយទាក់ទង ទៅនឹងកម្ពុជារបស់ រ៉ាឌី ម៉ម ហើយក៏ឃើញថានយោបាយរបស់គាត់លែងមានប្រសិទ្ធិភាពថែមទៀត... ពួកគេបន្តថា ចង់ឃើញមនុស្សជំនាន់ថ្មី មានឋាមពលថ្មី មានគំនិតថ្មីចេញមកដឹកនាំនយោបាយថ្មី ក្នុងតំបន់ ពីព្រោះពេលវេលាមកដល់សម្រាប់ពួកអ្នកជំនាន់ថ្មីហើយ សម្រាប់ធ្វើឲ្យសង្គមរីកចំរើន។

**សំនួរៈ តើលោក រាឌី ម៉ម បានសម្តែងការចុះចាញ់ចំពោះអ្នកឈ្នះ ដែលជាវប្បធម៌បោះឆ្នោត ដែរឬទេ?**

តារា ហុងៈ គាត់បានទូរស័ព្ទមក«ជូនពរ»ខ្ញុំនៅថ្ងៃបន្ទាប់ ដែរ តែមិនទាន់ជួបផ្ទាល់នៅឡើយទេ!

**សំនួរៈ នៅថ្ងៃទី៥វិច្ឆិកាខាងមុខនេះ នឹងមានការបោះឆ្នោតប្រធានាធិបតីសហរដ្ឋអាមេរិកដែរ លោក តារា ហុង ដែលជាសមាជិកគណបក្សប្រជាធិបតេយ្យ ដូចលោកស្រី កាមាឡា ហារីស ដែរនោះ**

**តទៅទំព័រទី២៣**


**The Lowell Regional Transit Authority**
**Announces**
**A Temporary Fare Free Pilot Program Commencing**
**December 1, 2024**
**And Continues Through September 30, 2025**
**(Fares may resume 10/1/2025 Subject to State Funding)**

**The Lowell Regional Transit Authority Announces A Temporary Fare Free Pilot Program Commencing December 1, 2024 And Continues Through September 30, 2025 (Fares may resume 10/1/2025 Subject to State Funding).**

**អាជ្ញាធរដឹកជញ្ជូនក្នុងតំបន់ឡូវែល**

**សូមប្រកាស**

**កម្មវិធីសាកល្បងឥតគិតថ្លៃបណ្តោះអាសន្នចាប់ផ្តើម នៅថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០២៤**

**និងបន្តរហូតដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២៥**

**(គិតថ្លៃឡើងវិញនៅថ្ងៃទី ១០/១/២០២៥ អាស្រ័យលើការផ្តល់មូលនិធិរបស់រដ្ឋ)**

**The LRTA wants to Thank**
**Governor Maura Healey and Lieutenant Governor Kim Driscoll,**
**as well as the Massachusetts State Legislature for funding this**
**Fare Free Transportation Pilot Program**
**that will greatly benefit our communities.**
**Lowell Regional TA Transit Authority**

**LRTA.com**

**LRTA សូមថ្លែងអំណរគុណអភិបាល Maura Healey និងអភិបាលរង Kim Driscoll**

**ក៏ដូចជាសភានីតិបញ្ញត្តិរដ្ឋម៉ាសាឈូសេត សម្រាប់ការផ្តល់មូលនិធិដល់កម្មវិធីសាកល្បងដឹកជញ្ជូនឥតគិតថ្លៃ ដែលនឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់សហគមន៍របស់យើង។**

**អាជ្ញាធរដឹកជញ្ជូនក្នុងតំបន់ឡូវែល**



**The Lowell Regional Transit Authority**

*Announces*




**A Temporary Fare Free Pilot Program Commencing**
**December 1, 2024**
**And Continues Through September 30, 2025**
(Fares may resume 10/1/2025 Subject to State Funding)

The LRTA wants to Thank Governor Maura Healey and Lieutenant Governor Kim Driscoll, as well as the Massachusetts State Legislature for funding this Fare Free Transportation Pilot Program that will greatly benefit our communities.

LRTA Lowell Regional Transit Authority

**LRTA.com**

តមកពីទំព័រទី ០៤

# បញ្ហាតម្លៃកសិផលចំពោះកសិករ...

រាល់ថ្ងៃហ្នឹងមិនដឹងថាខាងណាអោយពិតប្រាកដទេពិបាកដែរ ច្រូតដឹងថាច្រូតយើងច្រូតទៅលក់បានត្រឹមតែតម្លៃគេអ្នកកំណត់តើអ្នកទិញហ្នឹង តម្លៃតាមមាត់គេហា និយាយរួមទៅទាល់តែចាប់ពីអើ១០ឡើង បើក្រោម១០អត់ចំណេញទេ ទាល់តែស្រូវកើបពីម៉ាហិចតា៤ទៅ៥តោនទើបអាចចំណេញ បើថាក្រោមហ្នឹងអត់ចំណេញទេ គិតគូរអស់ហើយច្បាស់អស់ហើយ គិតមើលអត់ចំណេញទេ ម៉ាហិចតា៣តោនវាបាន៣លានៗគិតទៅអត់ចំណេញទេជាក់ស្តែងថ្ងៃទី៦ ខែកញ្ញា លោក ចាន់ ឌី ផល្លី បានផុសលើគណនីបណ្តាញសង្គមរបស់លោកពីទិដ្ឋភាពឈ្មួញចុះទិញស្រូវ ក្នុងឃុំសឿ នោះពុំដែលឲ្យ



រថយន្តធំៗប្រកសិផលខ្មែរទៅលក់នៅវៀតណាម

តម្លៃទាបក្រោម១០០០រៀល ធ្វើឲ្យកសិករខ្លះបង្ខំចិត្តលក់ទាំងខាតដើម វីដេអូនោះដែរលោកអំពាវនាវឲ្យមន្ត្រីកសិកម្មដោះស្រាយបញ្ហានេះ ល្ងាចឡើងក៏មានមន្ត្រីចុះទៅអង្គុយត្រួតពិនិត្យ ឃើញមានឈ្មួញដំឡើងថ្លៃលើសមួយពាន់រៀលវិញ ពេលនោះដែរកសិករខាងលើបានអោយដឹងថា មន្ត្រីទាំងនោះបានបន្ទោសលោកថា បានធ្វើការផុសវីដេអូញុះញង់បំពុលសង្គម លោកបញ្ជាក់ថាបញ្ហានេះជាការពិត ដោយលោកមានពលរដ្ឋទូទាំងឃុំជាសាក្សីខ្ញុំរាងអាក់អន់ស្រពន់ចិត្តទៅហ្នឹងក្រសួងដែរ គេមកគេៗថាយើងហ្នឹងឡាយបំពុលសង្គម និយាយខុសពីការពិតជាក់ស្តែង ខ្ញុំបានសរសេរបង់ដែលខ្ញុំបានលក់ស្រូវហ្នឹងបានប៉ុន្មានតម្លៃប៉ុន្មាន ក៏បាញ់ចូលផេកដែលគេឡាយអោយខ្ញុំមើលហ្នឹងបាញ់ចូលទៅទៀតបាញ់ចូលអោយគាត់មើល ហើយក៏មិនឃើញតបតដែរ ស្ងាត់ឈឹងដែរ គេសួរឈ្មោះសួរអីខ្ញុំដែរតើ ប៉ុន្តែខ្ញុំទៅខ្លាចអីខ្ញុំ ខ្ញុំគ្មានទៅនិយាយរឿននយោបាយអីទេ ខ្ញុំនិយាយតែរឿងតាធ្វើស្រែធ្វើចម្ការទេ គ្រាន់ថាអាណិតអ្នកស្រែតែប៉ុន្នឹង អ្នកស្រែក៏គេគាំទ្រទាំងអស់នៀកអ្នកភូមិអ្នកឃុំខ្ញុំនេះហាបើថាគេមកមានបញ្ហាជាមួយខ្ញុំគេចេញមុខទាំងអស់នេះក្រៅពីខេត្តបន្ទាយមានជ័យ កសិករនៅខេត្តពោធិ៍សាត់ក៏បានត្អូញត្អែរលើបណ្តាញសង្គម កាលពីថ្ងៃទី០៥ ខែកញ្ញា ដែរថាស្រូវមួយតោនលក់មិនបាន មួយលានរៀល ឡើយតែបើយោងតាមការចេញផ្សាយរបស់សហព័ន្ធស្រូវអង្ករកម្ពុជា កាលពីថ្ងៃទី០៤ ខែកញ្ញា ស្រូវសើមក្នុងមួយគីឡូក្រាមអំពីតម្លៃចាប់ពី១០៤០រៀល ដល់១៤៥០រៀល ស្រូវដែលមានតម្លៃខ្ពស់ជាងគេ គឺស្រូវសែនក្រអូប នៅស្រុកបវេល ខេត្តបាត់តំបង ទោះយ៉ាងណាតម្លៃកសិផលធ្លាក់ចុះតាមមាត់ឈ្មួញមិនមែនកើតឡើងតែលើផលដំណាំនោះឡើយ ដោយអ្នកចិញ្ចឹមសត្វក៏កំពង់តែជួបវិបត្តិតម្លៃនេះដូចគ្នា ដោយមានការនាំចូលកសិផលពីប្រទេសជិតខាងដោយនាំចូលលើសលប់ចូលមកទីផ្សាកម្ពុជា អ្នកចិញ្ចឹមទាយកពង នៅ ស្រុកឧត្តុងម៉ែជ័យ ខេត្តកំពង់ស្ពឺ បានឲ្យដឹងថាទោះបីឈ្មួញនៅតែទិញពងទាពីកសិករខ្មែរ តែពួកគេបញ្ចុះតម្លៃអោយធ្លាក់ចុះខ្លាំង ដោយសារតែលំហូរនាំចូលពីប្រទេសជិតខាង វាយលុកចូលទីផ្សារកម្ពុជាក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ លោកឲ្យដឹងថាបច្ចុប្បន្នពងទាលក់បានតម្លៃ៣០០ទៅ៣៥០រៀល ខណៈតម្លៃ៥០០រៀលទើបកសិករអាចកាត់ថ្លៃចំណីទា និងសល់ប្រាក់ចំណេញតិចតួច ចំពោះបញ្ហាលក់អត់ចេញវាមិនមែនអត់ចេញទេបង ឈ្មួញគេនៅតែយកចឹង ប៉ុន្តែដោយសារមួយរយៈនេះវាមានបញ្ហានាំចូលពីក្រៅប្រទេស

**តទៅទំព័រទី២១**

# Agricultural Prices for Farmers Face Recurring Crisis

From Page 04

price by more than a thousand riel per Kilogram of rice. At the same time, the farmer said that the officials blamed him for making a video to incite social pollution. He confirmed that this problem is true, because people all over the commune as witnesses, I am dissatisfied with the ministry officials, they come and say that we are polluting society, speaking the wrong truth.

I wrote down how much I sold the rice, how much the price was, and posted it in the group they gave me to look at, shot it again, posted it for them to see, and did not see the response. But I'm scared. I do not talk about politics, I only talk about farming, just pity the farmers, the farmers also support all villagers, my commune, if they have a problem with me, they leave. In addition, farmers in Banteay Meanchey and Pursat province also complained on social media.

On September 5, a ton of rice was not sold for one million Riel, but according to the release of the Cambodian Rice Federation on September 4. Wet rice per kilogram price from 1040 Riel to 1450 Riel, the highest price is fragrant rice in Bavel district, Battambang province.

Livestock farmers are also facing the same price crisis with the import of agricultural products from neighboring countries, with oversupply entering the Cambodian market but they have slashed prices due to the influx of imports from neighboring countries in recent months, he said, can reduce the cost of poultries and less profit. As for the problem of not selling out, the traders still take it, but for a while it has been a problem with importing too much from abroad, it makes the problem of duck eggs in the country, it drops the price to a low price.

It is not up to the sales level, but just in the meantime, the cost is more than the income we got back, so the problem of cheap agricultural products, no market has become a chronic problem in Cambodia under the control of Hun Sen's family and the CPP government for more than four decades, although the seventh mandate changed the new leader in the new position, Prime Minister Hun Manet in November 2023 set a policy priority in the sixth mandate. To develop the modern agricultural community, it has three main points: reduce production costs, increase crop quality standards and ensure the stability of farmers' markets.

Khim Phinong, spokesman for the Ministry of Forestry and Fisheries, could not be reached for comment on September 11, 2024, according to VOD, the local press calls for farmers to use Cambodian rice varieties, according to this official. Cambodian rice varieties are fragrant rice and Rumduol rice because the Ministry can easily solve the problem when rice prices fall. On the other hand, this type of rice can be exported to Europe for higher prices than rice varieties imported from overseas. The price of rice depends on the decision of the traders. However, the measures taken by the government are specific only on paper, but in practice for almost a year now, farmers still face the same problems as the previous government. The problem from the beginning of planting to the time of harvesting, with high prices of fertilizers, pesticides and animal feed until the time of sale, the price is low, leading to farmers losing their debts to banks, debtors selling pesticides.

At the same time, the influx of ag-

**Please see /21**



តមកពីទំព័រទី ២០

# បញ្ហាតម្លៃកសិផលចំពោះកសិករ...

ច្រើនពេកវាធ្វើអោយបញ្ហាពងទានៅក្នុងប្រទេសវាធ្លាក់តម្លៃទាប ធ្លាក់ក្នុងតម្លៃមួយដែលយើងមិនអាចទទួលយកបានចឹងហាណាស់បង វាមិនមែនចាល់ដល់ថ្នាក់លក់អត់ចេញទេបង ប៉ុន្តែគ្រាន់ថាក្នុងកម្លុងពេលឡូវហ្នឹង ការចំណាយវាច្រើនជាងចំណូលដែលយើងបានមកវិញចឹងហឹណាស់ បញ្ហាកសិផលលក់បានថោកគ្មានទីផ្សារ បានក្លាយជាបញ្ហារាំរ៉ៃនៅក្នុងប្រទេសកម្ពុជា ក្រោមការគ្រប់គ្រងរបស់គ្រួសារ លោក ហ៊ុន សែន និងរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា ជាង៤ទសវត្សន៍មកនេះ ទោះបីអាណត្តិទី៧នេះ បានផ្លាស់ប្តូរមេដឹកនាំថ្មីក៏ដោយ ក្នុងពេលកាន់តំណែងថ្មីៗ លោកនាយករដ្ឋមន្ត្រី លោក ហ៊ុន ម៉ាណែត កាលពីខែវិច្ឆិការ ឆ្នាំ២០២៣ បានដាក់ចេញគោលវិធីនយោបាយអតិភាពក្នុងអាណត្តិទី៦ ក្នុងគោលដៅរៀបចំអភិវឌ្ឍន៍ សហាគមន៍កសិកម្មទំនើប យន្តការកែប្រែសហាគមន៍កសិកម្មទំនើបនេះមាន៣ចំណុចសំខាន់ៗ គឺកាត់បន្ថយថ្លៃដើមផលិតបង្កើនស្តង់ដាគុណភាពដំណាំ និងធានាស្ថិរភាពដល់ទីផ្សារកសិករ លោក ឃឹម ហ្វីណុង អ្នកនាំពាក្យក្រសួងរុក្ខាប្រម៉ាញ់ និងនេសាទ មិនអាចទាក់ទងបានទេជុំវិញបញ្ហារឿងនេះ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤ នេះបើតាមការចុះផ្សាយរបស់VODទោះជាយ៉ាងណាអ្នកនាំពាក្យក្រសួងកសិកម្មរូបនេះបានផ្តល់បទសម្ភាសន៍ដល់សារព័តមានក្នុងស្រុក បានអំពាវនាវដល់ប្រជាកសិករប្រើប្រាស់ពូជស្រូវរបស់ខ្មែរវិញ បើតាមមន្ត្រីរូបនេះ ពូជស្រូវរបស់ខ្មែរគឺ ស្រូវសែនក្រអូប និងស្រូវផ្ការំដួល ដោយសារក្រសួងងាយស្រួលដោះស្រាយបញ្ហាពេលតម្លៃស្រូវធ្លាក់ចុះ ម្យ៉ាងទៀតស្រូវប្រភេទនេះអាចនាំចេញទៅកាន់អឺរ៉ុបបានតម្លៃខ្ពស់ ជាងពូជស្រូវនាំចូលពីបរទេសដោយតម្លៃស្រូវអាស្រ័យទៅលើការសម្រេចចិត្តរបស់ឈ្មួញ ទោះជាយ៉ាងនេះក្តីវិធានការដែលបានដាក់ចេញដោយរដ្ឋាភិបាលមានភាពជាក់លាក់តែនៅលើក្រដាស់ប៉ុណ្ណោះ តែការអនុវត្តជាក់ស្តែងជិតមួយឆ្នាំមកនេះ កសិករនៅតែជួបបញ្ហាដូចរដ្ឋាភិបាលអាណត្តិមុន ហើយបញ្ហាជួបតាំងពីតំបូងនៅពេល

តទៅទំព័រទី១៥

# Agricultural Prices for Farmers Face Recurring Crisis

From Page 20

ricultural products from neighboring countries into Cambodia, which is a factor that makes the price of domestic agricultural products fall and cannot compete because of higher production costs than sales.

Regarding this issue, Theng Savoeun, President of the Federation of Cambodian Farmers' Associations, said that the export and import of agricultural products is common in a free market country like Cambodia, but at the same time, the government through the Ministry of Agriculture must increase outreach to farmers such as selected rice varieties and to find a market to sell agricultural products at a reasonable price during the harvest season. The Royal Government as well as the Ministry of Agriculture, which is the state staff, must consider and encourage market research to be guaranteed at a reasonable price that makes farmers will not lose. Do not let some people get discouraged because the problem-solving factor in front of them encourages them to be confident and continue to grow crops and promote it, and good advice is to set up checks on middlemen who buy rice from farmers and low the prices, according to Theng Savoeun.

The Ministry of Forestry and Fisheries also released a report in the first half of 2024, Cambodia's agricultural exports reached more than 6 million tons, an increase of nearly 60 percent compared to the first half of 2023, an unprecedented increase in the last 5 years.

About 65 million tons of agricultural products have been exported to 77 target markets around the world, including more than 1,800 million US dollars' worth of non-rice agricultural products, more than 400 million US dollars' worth of rice products and more than 200 million US dollars' worth of rice products.

In 2023, agriculture contributed to socio-economic development, contributing about 22% of the country's gross domestic product by the local producers, according to Prime Minister Hun Manet, because they are still in crisis for many years if the government continues to allow traders to control the market, lowering prices at will during the harvest season.

យើងជឿថា ឆ្នាំល្អបំផុតរបស់អ្នកមកដល់ហើយ
(ឆ្នាំកន្លងទៅ ក៏ល្អសម្រាប់អ្នកដែរ)



Element Care PACE ជួយអ្នកឱ្យរស់នៅដោយឯករាជ្យនៅក្នុងសហគមន៍។

- ការថែទាំសុខភាពតាមបែបវេជ្ជសាស្ត្រ ថែទាំធ្មេញ និងថែទាំភ្នែកផ្ទាល់ខ្លួន ។
- មជ្ឈមណ្ឌលបើកបម្រើនៅពេលថ្ងៃ

មានការដឹកជញ្ជូន មានអាហារ និងសកម្មភាពសង្គម
ទាំងអស់នេះ អ្នកក៏អាចរក្សាសុខភាពល្អបំផុត។

Element Care | PACE

ស្វែងយល់បន្ថែម តើអ្នកឬមនុស្សជាទីស្រឡាញ់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរឬទេ៖
(877) 803-5564 (TTY 711) ElementCare.org

មិនគិតថ្លៃសម្រាប់អ្នកមានសិទ្ធិទទួលបាន MassHealth និង Medicare ។ សូមទាក់ទងមកយើងសម្រាប់តែ Medicare និងជម្រើសបង់ប្រាក់ដោយខ្លួនឯង។

អ្នកចូលរួមទទួលបានការថែទាំសុខភាពទាំងអស់ សេវាពេទ្យបឋម និងពេទ្យឯកទេស - និងសេវាសង្គ្រោះបន្ទាន់ផ្សេងទៀត ដែលអនុញ្ញាតដោយ PACE ឬទទួលខុសត្រូវទាំងស្រុង និងផ្ទាល់ខ្លួនចំពោះថ្លៃសេវាដែលគ្មានការអនុញ្ញាត។

ROSA & TAING LAW, LLC



Attorney Francisco J. Rosa
មេធាវី ហ្វ្រានស៊ីសស្កូ ជេ. រ៉ូសា



Attorney Andrew 'Bunna' Taing
មេធាវី អេនឌ្រូ ប៊ុណ្ណា តាំង

Concentrated in
Auto Accident
Personal Injury
Real Estate Closing
Immigration
Divorces
Child Custody
Bankruptcy

ជំនាញខាងផ្នែក៖
គ្រោះថ្នាក់រថយន្តគ្រប់ប្រភេទ
ការរងរបួសផ្ទាល់ខ្លួន
ការកាត់ឈ្មោះប្លង់ផ្ទះ
អន្តោប្រវេសន៍
ការលែងលះ
ការគ្រប់គ្រងថែរក្សាកូន
ក្ស័យធន

Main Office / Mailing Address
1550 Middlesex Street
Lowell, MA 01851

Revere Office
385 Broadway, Suite 305
Revere, MA 02151

978-458-0934 • at@rosataing.com

តមកពីទំព័រទី ២១

## បញ្ហាតម្លៃកសិផលចំពោះកសិករ...

បង្កបង្កើនផល ហូតដល់ពេលប្រមូលផលដោយជីថ្នាំកសិកម្ម និង ចំណីសត្វមានតម្លៃខ្ពស់ ដល់ពេលបានផលលក់ចេញទៅវិញបានតម្លៃទាប នាំអោយកសិករខាតដើម ជំពាក់ធនាគារ ជាប់បំណុលឈ្មួញលក់ជីថ្នាំកសិកម្ម ជាមួយគ្នានេះដែរការហូរចូលដំណាំកសិផល ពីប្រទេសជិតខាងចូលមកកម្ពុជាដែលជាកត្តាធ្វើអោយតម្លៃកសិផលក្នុងស្រុកធ្លាក់ចុះ ហើយមិនអាចប្រកួតប្រជែងបាន ក៏ព្រោះតែចំណាយថ្លៃផលិតខ្ពស់ជាងការលក់ចេញ ទាក់ទងនឹងបញ្ហារឿងនេះ លោក ថេង សាវឿន ប្រធានសមាគមន៍សហព័ន្ធសហគមន៍កសិករកម្ពុជា ថាការនាំចេញនាំចូលកសិផលគឺជារឿងធម្មតាក្នុងប្រទេសមានទីផ្សារសេរីដូចប្រទេសកម្ពុជា តែទន្ទឹមគ្នានេះរដ្ឋាភិបាលតាមរយៈក្រសួងកសិកម្មក៏ត្រូវបង្កើនការផ្សព្វផ្សាយ ដល់កសិករដូចជាការជ្រើសរើសពូជស្រូវ និងត្រូវរកទីផ្សារដែលត្រូវលក់ កសិផលបានតម្លៃសមរម្យ នៅរដូវប្រមូលផល រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងកសិកម្មដែលជាសេនាធិការរដ្ឋត្រូវតែគិតគូរត្រូវតែជម្រុញការរកស្វះស្វែងរកទីផ្សារត្រូវតែធានាបាននៅតម្លៃមួយសមស្រប ដែលធ្វើអោយកសិករនឹងលក់ទៅមិនមានការខាតបង់ ហើយកុំអោយមានអ្នកខ្លះបាក់ទឹកចិត្ត ពីព្រោះថាកត្តាការដោះស្រាយបញ្ហាចំពោះមុខនេះវាជួយជម្រុញដល់ពួកគាត់មានទំនុកចិត្តហើយវាជម្រុញអោយពួកគាត់មានទឹកបន្តក្នុង



ការដាំដុះបង្កបង្កើនផលហើយជាមួយនឹងការជម្រុញអោយមានការផ្សព្វផ្សាយ និងការណែនាំពីសេសគឺការរៀបចំត្រួតពិនិត្យទៅលើឈ្មួញកណ្តាល ដែលកំពុងតែប្រមូលទិញស្រូវពីប្រជាកសិករដែលកំពុងតែទម្លាក់ថ្លៃនេះផងដែរ នេះបើតាមយោងប្រសាសលោកថេង សាវឿន ក្រសួងពាណិជ្ជកម្មប្រម៉ាញ់ និងនេសាទក៏បានចេញរបាយការណ៍ថា ក្នុងឆមាសទី១ ឆ្នាំ២០២៤ ការនាំចេញកសិផលរបស់កម្ពុជា សម្រេចបានជាង ៦លានតោន កើនឡើងជិត ៦០ភាគរយ ធៀបនឹងឆមាសទី១ ក្នុងឆ្នាំ២០២៣ ដែលជាកំណើនមិនធ្លាប់មានក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះកសិផលប្រមាណ៦៥លានតោននេះ បាននាំចេញទៅកាន់ទីផ្សារគោលដៅចំនួន ៧៧ប្រទេស ទូទាំងពិភពលោក ក្នុងនោះក៏នាំចេញកសិផលក្រៅពីស្រូវអង្ករ មានទំហំទឹកប្រាក់ជាង ១៨០០លានដុល្លា កសិផលស្រូវជាង ៤០០លានដុល្លា កសិផលអង្ករជាង ២០០លានដុល្លា កាលពីឆ្នាំ២០២៣ វិស័យកសិកម្មបានចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមបានរួមចំណែកប្រមាណ ២២ភាគរយ នៃផលិតផលសរុបក្នុងប្រទេស នេះបើតាមការលើកឡើងរបស់នាយករដ្ឋមន្ត្រីលោក ហ៊ុនម៉ាណែត ទោះជាយ៉ាងនេះក្តីការនាំចេញទាំងនោះហាក់មិនបានដល់ដៃកសិករជាអ្នកផលិតក្នុងស្រុកទេក៏ពញ់ពោះ តែពួកគាត់នៅតែជួបវិបត្តិច្រើនឆ្នាំទៀត បើរដ្ឋាភិបាលនៅតែបណ្តែតបណ្តោយអោយឈ្មួញគ្រប់គ្រងទីផ្សារទម្លាក់តម្លៃតាមចិត្តនៅរដូវដែលពួកគេប្រមូលផល៕

តមកពីទំព័រទី ១១

## កម្ពុជាអាចនឹងបាត់បង់ដី៥១គីឡូម៉ែត្រ

ថាប្រទេសវៀតណាម បានធ្វើថ្នល់កៅស៊ូតាមចំណុចព្រែកដាក់ដាំ និង ពីប៉ុស្តិ៍ប្រប្រាង មកដាក់ដាងដោយបានជីកស្រះ និងសង់ប៉ុស្តិ៍យោធាតាម បណ្តោយព្រំដែន អូរដាក់ដាំ ស្ថិតនៅក្នុង ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរីវង់ជាប់ ឃុំខ្វាំងជិត ស្រុកដាក់ឡាង ខេត្តដាក់ណុង ប្រទេសវៀតណាម អូរដាក់ដាង មានចម្ងាយប្រមាណ ៨០០ម៉ែត្រ ពីច្រកទ្វារព្រំដែនដាក់ដាំ និង ប្រមាណ ៨០០ម៉ែត្រ ដូចគ្នាពីប៉ុស្តិ៍ត្រួតពិនិត្យវៀតណាម ដែលបានសាងសង់ក្នុងតំបន់មិនទាន់ឯកភាពគ្នារវាង កម្ពុជា និង វៀតណាម ប្រភពបញ្ជាក់ថា តំបន់ដាក់ដាំដាក់ហ៊្សិតមានផ្ទៃដី ៥១គីឡូម៉ែត្រក្រឡា ដែលកម្ពុជា វៀតណាមមិនទាន់ឯកភាពគ្នានៅឡើយ ចាប់ពីបង្គោលលេខ៥៥ ក្នុងស្រុកអូររាំង រហូតដល់បង្គោលលេខ៦០ មានប្រវែង ២៧គីឡូដោយវៀតណាមចង់កំណត់ព្រំដែនត្រឹមអូរដាក់ដាំ ឬដាក់ដាង ចំណែកខាងរដ្ឋាភិបាលកម្ពុជាចុះកំណត់ព្រំដែនយកត្រឹមអូរហុច ដែលវៀតណាមហៅថាអូរហ៊ុច រហូតដល់ អូរតាំងម៉ែ ដល់អូរផ្លោយ បានធ្លាក់មកដល់ទន្លេស្រែពក ដែល

ជាព្រំដែនចាស់តាំងពីសម័យអាណានិគមនិយមបារាំងមក លោក អ៊ុំ សំអាន ថាកាលដែលវៀតណាមគ្រប់គ្រងតំបន់ដាក់ដាំដាក់ហ៊្សិតក្នុងដែនដីមណ្ឌលគិរីនេះវាផ្តើមចេញពី លោក ហ៊ុន សែន ធ្វើឲ្យសន្ធិសញ្ញាព្រំដែនខុសច្បាប់ដែលគ្រប់គ្រងដោយវៀតណាមរស់ឡើងវិញនៅឆ្នាំ២០០៥ ក្រោមសារគម្រាមរំលាយស្ថាប័នព្រះមហាក្សត្រ ដើម្បីសម្រេចនូវមហិច្ឆតាវៀតណាម លេបទឹកដីខ្មែរ តាមក្រមព្រហ្មទណ្ឌ មាត្រា៤៤០ បានចែងថា អំពើប្រគល់ឲ្យរដ្ឋបរទេស ឬភ្នាក់ងារបរទេសនូវដែនដីជាតិទាំងស្រុង ឬមួយផ្នែកគឺជាអំពើក្បត់ជាតិត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត៕

តមកពីទំព័រទី ០៨

## បុណ្យភ្ជុំបិណ្ឌនៅឡូវ៉េល

ថេរវាទដូចខ្មែរយើងដែរ បានបញ្ឈប់ប្រារព្វពិធីបុណ្យភ្ជុំបិណ្ឌ រួចទៅហើយ តើហេតុអ្វី? ព្រះអង្គ មី ឡែមានសង្ខជីកាបន្តរថា«ចុទិបដិសន្ធិ មនុស្សដែលស្លាប់ទៅ ទៅកើតនៅទីដទៃ ប្រែរូបជាសត្វផ្សេង តាមគម្ពីរបុរាណនិយាយថា ប្រេតគឺជាអរូបីយ ដែលមករកយើងឲ្យជួយគេមើលយើងឃើញ យើងមើលគេមិនឃើញវិញទេ តែយើងបែរជាខ្លាចក៏មាន តែតាមពិតទៅមិនដែលនរណាមានយកភស្តុតាងណាមកបង្ហាញបានទេ អាត្មាយល់ថា យើងជួបជុំគ្នាធ្វើបុណ្យនេះគឺជាសទ្ធាខ្លាំងណាស់ដែលមានបំណងរួមគ្នា ផ្សាយនូវមេត្តាធម៌ ជួយដល់សព្វសត្វដែលមានទុក្ខទោសដូច្នោះ...ចំណែកឯប្រទេសដែលឈប់ប្រារព្វបុណ្យភ្ជុំបិណ្យ មានប្រទេសថៃ ប្រទេសភូមា ប្រទេសស្រីលង្ការ (ប្រទេសឡាវ មិនដឹងទេ).»។

ម្ហូបអាហារដ៏បរិបូរណ៍នឹង ធ្វើដ៏ប្រណិតសម្រាប់ជាចង្ហាន់ប្រគេនព្រះសង្ឃក៏ក្នុងបំណងឱទ្ទិសឲ្យទៅដល់បុព្វបុរសជាអ្នកមានគុណទាំងឡាយ ដែលបានបរិច្ចាកទៅដល់អ្នកដែលចែកឋានទៅហើយ ជាការសម្តែងទឹកចិត្តនឹករលឹកដឹងគុណពីកូនចៅ នៃគន្លងព្រះពុទ្ធសាសនាខ្មែរដែលនៅមានជីវិតនៅឡើយ។

ចង្ហាន់ដែលកូនចៅទាំងអស់ បានប្រគេនចំពោះព្រះសង្ឃនោះ គឺជាទានសម្តែងនូវសទ្ធាជ្រះថ្លារបស់កូនចៅសង្ឃឹមថានឹងបានបូជាតាមឱទ្ទិសតាមមេត្តាធម៌ ឲ្យបានទៅជាកុសល ជូនដល់មាតាបីតាជីដូនជីតាជាបុព្វបុរសដូចក្តីបំណង។ រីឯកូនចៅវិញ ក៏បានទទួលនូវផលបុណ្យ ទទួលបាននូវភាពរីករាយក្នុងចិត្ត ដោយបានសងគុណមនុស្សជាទីស្រឡាញ់របស់ខ្លួនបានសម្រេច ។ រីឯវត្តអារាមទាំងឡាយវិញ ក៏បានទទួលនូវការឧបត្ថម្ភយ៉ាងសមរម្យ ពីសំណាក់«ទាន»របស់ពុទ្ធបរិស័ទ ជាបច្ច័យផងនឹងជាសម្ភារៈផង ឲ្យអាចមានដំណើរការ ជា«ទីសក្ការៈរបស់ប្រជាជន»ក្នុងតំបន់តូចមួយ នៃសហរដ្ឋអាមេរិកថែមទៀត ៕

តមកពីទំព័រទី ០១

## អ្នកគួរដឹងពីថ្ងៃបោះឆ្នោតនៅសហ...

៣ ដំណែអសមាជិកសភាសហរដ្ឋអាមេរិក (Representative in Congress)

៤ ដំណែងទីប្រឹក្សាអភីបាលរដ្ឋ (Concillor)

៥ ដំណែអសមាជិកព្រឹទ្ធសភាប្រចាំរដ្ឋម៉ាសាឈូសិត (Senator in State MA)

៦ ដំណែហសមាជិសភារដ្ឋម៉ាសាឈូសិត (Representative in State MA)

៧ ដំណែងមន្ត្រីចុះបញ្ជីកម្មសិទ្ធ (Register of Deeds)


ប្រជាពលរដ្ឋបោះឆ្នោត"ផ្ញើសំលេង"នៅថ្ងៃទី៣០ វិច្ឆិកា នៅសាលាក្រុងឡូវែល

៨ ដំណែងក្រឡាបញ្ជី (Clerk of Couts)

៩ ដំណែងក្រុមប្រឹក្សាភិបាលប្រចាំខោងធី (County Commissionner)

១០ដំណែងមន្ត្រីតុលាការមរតកសាសន៍ (Register of Probate)

ការបោះឆ្នោត«ផ្ញើរសម្លេង» អាចធ្វើទៅបានរហូតដល់ថ្ងៃទី១វិច្ឆិកា២០២៤ គឺត្រូវបញ្ជូនសន្លឹកបោះឆ្នោតលោកអ្នកឲ្យទៅដល់សាលាក្រុង ការិយាល័យបោះឆ្នោត ឲ្យបានមុនថ្ងៃទី១វិច្ឆិកា២០២៤ ។ សម្រាប់កាអញ្ជើញទៅបោះឆ្នោត នៅថ្ងៃទី ៥ វិច្ឆិកា លោកអ្នកត្រូវអញ្ជើញទៅរក មណ្ឌលបោះឆ្នោតលោកអ្នក ដើម្បីទម្លាក់សន្លឹកឆ្នោតក្នុងប្រអប់ ពីម៉ោង ៧ ដល់ម៉ោង ៨ ល្ងាច ។

ប្រជាប្រិយភាពចុងក្រោយ នៃបេក្ខនារី នឹង បេក្ខជន ប្រធានាធិបតី

នៅ១សប្តាហ៍មុនថ្ងៃផ្តាច់ព្រ័ត្រ ឌណាល ត្រាំ នឹង កាម៉ាឡា ហារីស មានប្រជាប្រិយភាពស្មើគ្នា

បេក្ខនារី កាម៉ាឡា ហារីស នឹង បេក្ខជន ឌណាល ត្រាំ កំពុងបន្តរដំណើរយ៉ាងមមាញឹក ទៅឃោសនានៅតំបន់រដ្ឋទាំង៦ដែល «ឃ្លីងឃ្លោង»ម្តងទៅខាងគណបក្សប្រជាធិបតេយ្យ ម្តងទៅខាងគណបក្សសាធារណរដ្ឋ ពីព្រោះអ្នកទាំង២ កំពុងមានប្រជាប្រិយភាពប្រហាក់ប្រហែលគ្នា ក្នុងទូរលេខ៤៨%ដូចគ្នា ដូច្នេះគឺនៅរដ្ឋ«ឃ្លីងឃ្លោង»ទាំងនោះ ហើយដែលកំណត់ថានរណានឹងឡើងជាប្រធានាធិបតី បើយកឈ្នះលើរដ្ឋទាំង៦នោះបាន គឺរដ្ឋមីឈីគ្ហាន់ រដ្ឋហ្វីឡាដែលហៀរដ្ឋការ៉ូឡាយណាខាងជើង រដ្ឋញូយ៉ក...៕

តមកពីទំព័រទី ១០

## តារា ហុង ឈ្នះឆ្នោតជុំទី១ សម្រាប់

**នឹងមើលឃើញថាតើក្រុងឡូវែលដ៏មានពលរដ្ឋខ្មែរអាមេរិកាំងយ៉ាងច្រើន**


បេក្ខជនគណបក្សសាធារណរដ្ឋម៉ាសាឈូសេតសម្រាប់ថ្ងៃបោះឆ្នោត៥វិច្ឆិកា
១-តារា ហុង ២-អ៊ី នីសេគ្គ័រ ៣-អែត ខេណើឌី ៤-វណ្ណា ហ្វាំង

**រស់នៅទីនោះ នឹងមានឥរិយាបទបែបណា ចំពោះការបោះឆ្នោតដ៏សំខាន់នោះ?**

តារា ហុង: ខ្ញុំជឿថាប្រជាពលរដ្ឋខ្មែរនៅឡូវែលនេះនឹងចេញទៅបោះឆ្នោតយ៉ាងច្រើនកុះករ ខ្លួនខ្ញុំដែលជាសមាជិកគណបក្សប្រជាធិបតេយ្យ នឹងគាំទ្រដល់បេក្ខភាពរបស់អនុប្រធានាធិបតី កាមាឡា ហារីស នឹងអភិបាលរដ្ឋ ធីម វ៉ល ក្នុងការប្រកួតដំណែងប្រធានាធិបតី ជាមួយលោកឌណាលត្រាំខាងគណបក្សសាធារណរដ្ឋ។

**ព័ត៌មានបន្ថែម:**

**លោក តារា ហុង បានជាប់ ជាស្ថាពរ ជាតំណាងរាស្ត្រ កាលពីថ្ងៃ បោះឆ្នោត ទី៥ វិច្ឆិកា ២០២៤ នេះរួចហើយ ៕**


យើងធ្វើឲ្យការថែទាំសុខភាពងាយស្រួល

Neighborhood មាន
គម្រោងដែលមានតម្លៃសមរម្យសម្រាប់៖
• កុមារ និងក្រុមគ្រួសារ
• បុគ្គលម្នាក់ៗ
• អាជីវកម្មខ្នាតតូច

We make health care **easy.**

Neighborhood has affordable plans for:
• Children and families
• Individuals
• Small businesses

Neighborhood Health Plan OF RHODE ISLAND™

សូមទាក់ទងមកយើងខ្ញុំនៅថ្ងៃនេះ ដើម្បីស្វែងយល់បន្ថែម!
Contact us today to learn more!
1-401-459-6075 (TTY 711)
www.nhpri.org


តមកពីទំព័រទី ០៧

## អង្គការសហប្រជាជាតិទាញសញ្ញា

ប្រជាជន ។ ប្រជាជនដែលដើរលុយទឹកនៅតាមផ្លូវ នឹងក្នុងផ្ទះរបស់ខ្លួនបារម្ភថា ភ្លៀងនឹងបន្តធ្លាក់ ទឹកនឹងឡើងខ្ពស់ ពួកខ្លួននឹងគ្មានកន្លែងសុវត្ថិភាពទៀតទេ នោះក៏ដោយសារតែបឹងរក្សាទឹកជាច្រើន នៅជុំវិញទីក្រុងបានត្រូវលុបបំបាត់ នឹងលូបង្ហូរទឹកចេញ បានត្រូវស្ទះដោយសារទឹកទន្លេមេគង្គ បានឡើងខ្ពស់ជាងកំពស់ទឹកដែលត្រូវហូរចេញ ។

នៅមានការខូចខាតដោយទឹកជំនន់នៅប្រទេសជាច្រើនទៀត រាប់មិនអស់ តែបើយោងទៅតាមអង្គការពិភពលោក OMM បាននិយាយថា សេចក្តីសង្ឃឹមនៅមានផ្ទាំងស្រូបកំដៅព្រះអាទិត្យយកទៅបង្កើតអគ្គីសនី សម្រាប់ប្រើក្នុងផ្ទះ នឹងកសិដ្ឋាន ឬក៏ការប្រើកង្ហារយកកម្លាំងខ្យល់ មកបង្វិលម៉ាស៊ីនធ្វើអគ្គីសនី សម្រាប់ប្រើក្នុងរោងចក្រ ឬក៏ក្នុងអាគាររដ្ឋបាលជាដើមបានកើនចំនួនដល់ទៅ២ដង តែក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ បានន័យថា ការប្រើកំដៅដោយដុតប្រេង«កាបោនអុកស៊ីដ»បានថយចុះជាបន្តរបន្ទាប់ទៅហើយ៕

## Lowell Primary Care Center

## មណ្ឌលថែទាំសុខភាព Lowell

1075 Westford Street, Unit 204
Lowell, MA 01851 • (978) 455-7992

BAYON MEDICAL GROUP
BMG

## Lynn Primary Care Center

## មណ្ឌលថែទាំសុខភាព Lynn

280 Union Street, Unit 402
Lynn, MA 01901 • (781) 780-7755



**Chhan Touch, FNP-BC**
ឆាន់ ទូច



**Practice Manager**
**Channa Khan, CMA**
អ្នកគ្រប់គ្រងគ្រូពេទ្យ
ចាន់ណា ខាន់



**Sophor Chhour, LMHC**
សុភ័រ ឈួ



**Nalyne Dom, FNP-BC**
ណាលីន ដំ



**Nida Lam, FNP-BC**
នីដា ឡាម



**Maredy Sar, DNP, NP-C**
ម៉ារីឌី ស



**Miadette Pheng-Phal, DNP, NP-C**
មីយ៉ាដេត ផេងផល

## Now Accepting New Patients

## ឥឡូវនេះ បើកទទួលអ្នកជំងឺថ្មី

### *Family Medicine*
*ថែទាំសមាជិកគ្រួសារ*

### *Behavioral Health*
*ថែទាំសុខភាពផ្លូវចិត្ត*

**We Accept MassHealth, Medicare and Other Health Insurances**
**Our Staff Speaks Khmer**

យើងទទួល **MassHealth** **Medicare** និងការធានារ៉ាប់រងសុខភាពផ្សេងៗ
បុគ្គលិករបស់យើងនិយាយភាសាខ្មែរ